# អាជ្ញាធរអប្សរា និង សហគមន៍



# អារម្ភកថា



«អង្គរ» ជារមណីយដ្ឋានដែលមានជីវិតរស់រវើក និងត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩២។ ប្រាង្គប្រាសាទ ព្រៃឈើ និងសហគមន៍មនុស្ស គឺជាសមាសធាតុផ្សំយ៉ាងសំខាន់ក្នុងការកំណត់តម្លៃលេចធ្លោជាសកលរបស់រមណីយដ្ឋានអង្គរ និងមានឥទ្ធិពលទៅលើគ្នាទៅវិញទៅមក។ តាមរយៈសមាសធាតុផ្សំនេះ អារ្យធម៌ខ្មែរដ៏អស្ចារ្យដែលបានលេចធ្លោយ៉ាងត្រដែតក្នុងកំឡុងសម័យអាណាចក្រខ្មែរនាដើមសតវត្សទី៩ រហូតដល់សតវត្សទី១៥ នៅតែរំលេចចេញយ៉ាងច្បាស់ក្នុងពេលបច្ចុប្បន្ននាសតវត្សទី២១។ប្រសិនបើមានសមាសធាតុផ្សំណាមួយបានបាត់បង់នូវតម្លៃលេចធ្លោ ជាលក្ខណៈសត្យានុម័តនោះ ក៏នឹងបណ្តាលឲ្យអង្គរដែលជាកេរមរតកដ៏អស្ចារ្យនៃមនុស្សជាតិបាត់បង់នូវតម្លៃលេចធ្លោដែរ។ ដើម្បីថែរក្សា ការពារ និងលើកតម្លៃលេចធ្លោនៃសមាសធាតុផ្សំទាំងនេះឲ្យបានគង់វង្សស្ថិតស្ថេរចីរកាល អាជ្ញាធរអប្សរាមានតួនាទីយ៉ាងសំខាន់ក្នុងការជួសជុល អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។ ទស្សនាវដ្ដីដែលមានចំណងជើងថា "អាជ្ញាធរអប្សរា និងសហគមន៍" ត្រូវបានចងក្រងដើម្បីរំលេចនូវរាល់សមិទ្ធផលនានា ដែលអាជ្ញាធរអប្សរាសម្រេចបានជាប្រវត្តិសាស្ត្រនាពេលកន្លងមក ជាពិសេសពាក់ព័ន្ធការងារអភិវឌ្ឍប្រកបដោយចីរភាពសហគមន៍មនុស្សដែលរស់នៅជុំវិញតំបន់រមណីយដ្ឋានអង្គរ។ គួរកត់សម្គាល់ថា រមណីយដ្ឋានអង្គរមានទំហំផ្ទៃដី៤០១គីឡូម៉ែត្រក្រឡា គ្របដណ្ដប់លើទីតាំងភូមិសាស្ត្រ១១២ភូមិ ២១ឃុំ-សង្កាត់ និង០៥ក្រុង-ស្រុកនៃខេត្តសៀមរាប។ រីឯចំនួនមនុស្សរស់នៅក្នុងតំបន់នេះក៏មានការកើនឡើងជាគំហុក គឺនៅឆ្នាំ១៩៩៣ប្រជាពលរដ្ឋមានប្រមាណតែ២២,០០០នាក់ ហើយនៅឆ្នាំ២០០៥ ចំនួននេះបានកើនឡើង៥ដងមកដល់ប្រមាណ១០០,០០០នាក់ និងបន្តកើនឡើងដល់ប្រមាណ១៣០,០០០នាក់នៅឆ្នាំ២០១២។ ការកើនឡើងនូវចំនួនមនុស្សរស់នៅយ៉ាងគំហុកបែបនេះ បានបណ្តាលឲ្យប៉ះពាល់ដល់សមាសធាតុផ្សំចម្បងៗ ទាំងបីខាងលើហើយក៏អាចមានផលអវិជ្ជមានដល់កិច្ចការអភិរក្សដែរដូចជាការប្រើប្រាស់បរិមាណទឹកក្រោមដីច្រើនដែលអាចធ្វើឲ្យមានបញ្ហាដល់គ្រឹះប្រាសាទ ការហូរចូលច្រើននូវមនុស្សចំណូលថ្មី ការកើនឡើងនូវចំនួនខ្នងផ្ទះ ការប៉ះពាល់ដល់ជំនឿ និងទំនៀមទម្លាប់របស់អ្នកស្រុក ព្រមទាំងការប្រឈមនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងគោលបំណងបញ្ចៀសនូវផលប៉ះពាល់អវិជ្ជមានទាំងនោះ ជាពិសេសរក្សាឲ្យបានដាច់ខាតទាំងតម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋានអង្គរ និងទាំងការលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ អាជ្ញាធរអប្សរាបានបំពេញយ៉ាងជោគជ័យនូវការងារជាច្រើនសំដៅការអភិវឌ្ឍសហគមន៍ទូទៅ។ ជាក់ស្តែងតាមរយៈការស្តារ ជួសជុលប្រព័ន្ធផ្លូវទឹក និងប្រឡាយបុរាណដែលខូចខាត អាជ្ញាធរអប្សរាបានធ្វើឲ្យប្រព័ន្ធធារាសាស្ត្រអង្គរដែលជាកេរមរតកដូនតាមានជីវិតជាថ្មីឡើងវិញហើយបានបំពេញជាថ្មីនូវតួនាទីជាចម្បងក្នុងការរក្សាលំនឹងគ្រឹះប្រាង្គប្រាសាទ និងស្រោចស្រពសម្រាប់វិស័យកសិកម្ម។ ទេស-ភាពវប្បធម៌ដ៏ប្រណីតដែលជិតជាមជាប់ជាមួយនឹងវិស័យកសិកម្មជាច្រើនសតវត្ស ត្រូវបានរំលេចចេញជាថ្មីតាមរយៈការពង្រីកវិសាលភាពដាំដុះ និងធ្វើស្រែចម្ការ។ ដោយឡែកដើម្បីរួមចំណែកថែរក្សាប្រពៃណីទំនៀមទម្លាប់អ្នកស្រុកអង្គរ អាជ្ញាធរអប្សរាបានបង្កើតគម្រោងស្រាវជ្រាវនានា និងបានបង្កើតលំនាំបទដ្ឋានពីការគ្រប់គ្រងការពារបេតិកភណ្ឌអរូបី ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីពិគ្រោះពិភាក្សា និងផ្លាស់ប្តូរយោបល់ជាលក្ខណៈទូលំទូលាយ លើសេចក្តីព្រាងស្តីពីលំនាំបទដ្ឋានខាងលើ ដោយមានការចូលរួមពីព្រះសង្ឃ អាជ្ញាធរមូលដ្ឋាន ព្រមទាំងចាស់ព្រឹទ្ធាចារ្យក្នុងមូលដ្ឋាន និងតំណាងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ផងដែរ។ ក្នុងសកម្មភាពជាក់ស្តែងអាជ្ញាធរអប្សរា តាមរយៈក្រុមការងារសហគមន៍បានចូលរួមលើកកម្ពស់វប្បធម៌ប្រពៃណី ទំនៀមទម្លាប់របស់របស់អ្នកស្រុកអង្គរ ដូចជាការចូលរួមសកម្មភាពជាមួយគាត់ដូចជាពិធីកាន់បិណ្ឌ បុណ្យកឋិនជាដើម និងចូលរួមវេទិកាក្នុងពិធីប្រពៃណីផ្សេងៗ៕






មាតិកា


១.សេចក្តីផ្តើម....................................................................................................................................................៤
២.បេតិកភណ្ឌ និងសហគមន៍...................................................................................................................................៦
៣.ប្រព័ន្ធធារាសាស្ត្រអង្គរ..........................................................................................................................................៨
៤.ការរស់រានជាថ្មីឡើងវិញនូវប្រព័ន្ធធារាសាស្ត្រអង្គរ ១០
-សំណង់បញ្ចៀសទឹកជំនន់ ទ្វារទឹក និងប្រព័ន្ធស្រោចស្រព...................................................១៤
៥.ការងារគ្រប់គ្រងប្រព័ន្ធស្រោចស្រពបារាយណ៍ខាងលិច ៣១
-សហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ខាងលិច..............................................................................៣៤
៦.ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ៣៦
-ស្ពាន (ស្ពានបេតុង,ស្ពានបេឡេ).....................................................................................................................៣៨
-ផ្លូវប្រភេទ DPST( ផ្លូវ៦០,កំណាត់ផ្លូវ៦០ចំណុចT5,ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ)......................៤៦
-ផ្លូវអភិវឌ្ឍន៍ជនបទ(ផ្លូវបេតុងនៅផ្សារគោកស្នួល,ផ្លូវក្រាលគ្រួសក្រហម,ផ្លូវដីស).............៤៣
៩.អាជ្ញាធរជាតិអប្សរាចូលរួមការងារសង្គម ៥៨
-ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា.................................................................................៦០
-សកម្មភាពចែកសម្ភារៈទ្រទ្រង់សុខភាពម្តាយ និងទារក...................................................................៦២
-អាជ្ញាធរអប្សរាទំនុកបម្រុងអ្នកមានទេពកោសល្យ.....................................................................................៦៤
-អាជ្ញាធរអប្សរាផ្តល់អាជីពការងារដល់ប្រជាពលរដ្ឋ.....................................................................................៦៦
១០.អាជ្ញាធរជាតិអប្សរាចូលរួមលើកតម្លៃប្រពៃណី ទំនៀមទម្លាប់ និងសាសនា ៦៨
-ពិធីបុងក្រឡាន បួងសួងសុំទឹកភ្លៀង បុណ្យធ្វងផ្លូវ គោរជុកឬគោរកំប៉ោយ ៧០
១១.គម្រោងអភិវឌ្ឍន៍សហគមន៍ ៧៧
-ការងារអភិវឌ្ឍន៍កសិកម្ម និងសហគមន៍..................................................................................................៨០
-គម្រោងភូមិធម្មជាតិរុនតាឯក.........................................................................................................................៨៤
-សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ទេសចរណ៍បារាយណ៍រាជដាក.....................................................៩០
-សហគមន៍ទេសចរណ៍បន្ទាយស្រី..........................................................................................................................៩២


















១២.គម្រោងអភិវឌ្ឍន៍សហគមន៍ សហការជាមួយដៃគូរអន្តរជាតិ ៩៤

-សហគមន៍អប់រំបេតិកភណ្ឌ........................................................................៩៦

-សហគមន៍សិប្បកម្ម................................................................................៩៨

-សហគមន៍កុដិសូរ..................................................................................១០០

-ស្ថានីយ៍សាកអាគុយដោយថាមពលពន្លឺព្រះអាទិត្យ............................................១០២

-ក្រុមជួយខ្លួនឯង(សហគមន៍សន្សំប្រាក់)...........................................................១០៤

១២.អាជ្ញាធរជាតិអប្សរា និងការងារបរិស្ថាន ១០៦

-ព្រៃការពារបុរាណដ្ឋានតំបន់ប្រាសាទអ្នកតា(លើខ្នងភ្នំគូលែន)............................១០៨

-ការដាំកូនឈើឡើងវិញ..............................................................................១១០

១៣.សម្រង់មតិ៖ ទាំងអស់គ្នាដើម្បីអង្គរ ១១២

១៤.សំឡេងសហគមន៍នៃរមណីយដ្ឋានអង្គរ ១១៥

១៤.បញ្ជីរាយនាមក្រុមការងារសហគមន៍ទាំង៧ក្រុម ១១៨













# សេចក្ដីផ្ដើម

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា" ត្រូវបាន **ព្រះមហាវីរក្សត្រ ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ឡាយព្រះហស្តលេខាបង្កើតនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ។ ស្របតាមខ្លឹមសារនៃព្រះរាជក្រឹត្យខាងលើអាជ្ញាធរអប្សរាមានបេសកកម្មចម្បងជាប្រវត្តិសាស្ត្រដើម្បីរៀបចំការងារគ្រប់គ្រងអភិរក្ស ជួសជុលនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរដែលមានទំហំ៤០១គីឡូម៉ែត្រក្រឡានិងតំបន់ផ្សេងទៀតដែលគ្របដណ្ដប់ខេត្តសៀមរាបទាំងមូល។

ដោយអនុលោមតាមបេសកកម្មដែលមានជាធរមាន អាជ្ញាធរអប្សរា បានកំណត់នូវការងារជាអាទិភាព និងប្ដេជ្ញាបំពេញភារកិច្ចរបស់ខ្លួនដោយផ្ដោតលើគោលការណ៍ធំៗចំនួន០២ គឺ "អភិរក្សដើម្បីអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ដើម្បីអភិរក្ស" ។ ជាការអនុវត្តជាក់ស្ដែងនៃគោលការណ៍ដ៏សំខាន់នេះ អាជ្ញាធរអប្សរាកំណត់ទិសដៅភារកិច្ចសំខាន់ៗដូចជា ៖

១-កិច្ចការអភិរក្ស និងជួសជុលប្រាង្គប្រាសាទ ។

២-ការងារអភិវឌ្ឍន៍នានា សំដៅលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដល់ការរីកវត្តវិស័យទេសចរណ៍ ។

៣-ការងារអភិវឌ្ឍន៍សហគមន៍មនុស្សដែលរស់នៅជុំវិញរមណីយដ្ឋានអង្គរ។

តាមរយៈការកំណត់ទិសដៅបែបនេះហើយ អាជ្ញាធរអប្សរាបានរៀបចំផែនការយុទ្ធសាស្ត្ររួម និងផែនការសកម្មភាពដោយឡែករួមបញ្ចូលទាំងធនធានមនុស្ស និងហិរញ្ញវត្ថុដើម្បីទ្រទ្រង់ភារកិច្ចនីមួយៗឲ្យបានជោគជ័យ។

ជាក់ស្ដែង ក្នុងចក្ខុវិស័យវែងឆ្ងាយសំដៅចូលរួមលើកកម្ពស់កម្រិតជីវភាពរបស់បងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ ក៏ដូចជាលើកតម្លៃរូបីនិងអរូបីនៃបេតិកភណ្ឌដ៏បវរនៃរមណីយដ្ឋានអង្គរ ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា បានបង្កើតក្រុមការងារសហគមន៍ចំនួន ០៧ក្រុម ដើម្បីផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបានយល់ដឹងអំពីតួនាទី សមិទ្ធផលការងារថ្មីៗ ព្រមទាំងផលប្រយោជន៍នៃការចូលរួមអភិរក្សនិងអភិវឌ្ឍន៍ផ្សេងៗក្នុងរមណីយដ្ឋានអង្គរដោយអាជ្ញាធរអប្សរា។ម្យ៉ាងវិញទៀតនោះ ក្រុមការងារសហគមន៍នេះក៏មានភារកិច្ចដើម្បីចុះជួបប្រាស្រ័យទំនាក់ទំនងដោយផ្ទាល់ជា

មួយប្រជាពលរដ្ឋ ជាអ្នកផ្តល់ប្រឹក្សាយោបល់ និងសេវាកម្មផ្សេងៗដល់មូលដ្ឋាននៅហ្នឹងកន្លែងជូនប្រជាពលរដ្ឋ។ ជាពិសេសនោះគឺធ្វើការផ្តល់ជូននូវការអនុញ្ញាតសាងសង់ផ្ទះសម្បែង សំណង់តូចតាចផ្សេងៗជុំវិញផ្ទះ បង្គន់អនាម័យ ជួសជុលជញ្ជាំងផ្ទះ ដំបូលផ្ទះដោយប្រជាពលរដ្ឋពុំចាំបាច់ចំណាយពេលធ្វើដំណើរមកទីស្នាក់ការអាជ្ញាធរអប្សរាឡើយ។

លើសពីនេះទៀតនោះ ក្រុមការងារសហគមន៍ក៏មានតួនាទីជាបណ្តុំព័ត៌មានដែលផ្សារភ្ជាប់អាជ្ញាធរអប្សរាជាមួយប្រជាពលរដ្ឋតាមរយៈការប្រាស្រ័យទំនាក់ទំនងនិងទទួលយករាល់សំណូមពរពីសំណាក់ប្រជាពលរដ្ឋស្តីពីការស្តារប្រឡាយ-លូ ជួសជុល-កសាងផ្លូវថ្នល់ ទ្វារទឹក អណ្តូងទឹក និងសុំកូនឈើជាដើម។ ការជួយសម្រួលដល់ការលើកតម្កើងសេដ្ឋកិច្ចគ្រួសារនិងជីវភាពរបស់នៅប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋតាមរយៈការលើកកម្ពស់កម្រិតជំនាញនិងបង្កើតអាជីពការងារជូនពួកគាត់ក៏ជាកិច្ចការចម្បងផ្សេងៗទៀតដែលអាជ្ញាធរអប្សរាបានបំពេញរួចរាល់ហើយដែរ។ជាក់ស្តែងអាជ្ញាធរអប្សរាបានជួយបណ្តុះបណ្តាលប្រជាពលរដ្ឋឲ្យចេះចិញ្ចឹមសត្វ ដាំបន្លែ សន្សំប្រាក់ ធ្វើសិប្បកម្មចម្លាក់ បង្កើតសហគមន៍ទេសចរណ៍និងមុខរបរជាច្រើនផ្សេងទៀតផង។

ជាការចូលរួមចំណែក និងឆ្លុះបញ្ចាំងអំពីទឹកចិត្តអាណិតស្រឡាញ់ប្រជាពលរដ្ឋ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា បានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ស្ត្រីទើបប្រសូតបុត្រធីតា ព្រមទាំងបានបរិច្ចាគថវិកាផ្ទាល់ខ្លួនដើម្បីរៀបចំសម្ភារៈទ្រទ្រង់សុខភាពម្តាយនិងទារក ជូនស្ត្រីទាំងនោះទៀតផង។

# បេតិកភណ្ឌ និងសហគមន៍

សហគមន៍មនុស្សបុរាណជាអ្នកបង្កើតបេតិកភណ្ឌ និងបន្សល់ទុកឲ្យមនុស្សជំនាន់ក្រោយថែរក្សា។ បេតិកភណ្ឌបានបង្ហាញស្នាដៃ និងភាពថ្កុំថ្កើងនៃអារ្យធម៌របស់ដូនតា។ ជាក់ស្ដែងអង្គរ គឺជាបេតិកភណ្ឌដ៏មហស្ចារ្យរបស់មនុស្សលោក ដែលធ្វើឲ្យពិភពលោកទទួលស្គាល់ថាខ្មែរធ្លាប់មានអារ្យធម៌ដ៏រុងរឿងរាប់ពាន់ឆ្នាំមកហើយ។ ចំពោះខ្មែរផ្ទាល់អង្គរជាមរតកវប្បធម៌គ្មានអ្វីប្រៀបផ្ទឹមនៃប្រជាជាតិខ្លួន។ កេរដំណែលបុរាណដ៏ច្រើនលើសលុបដែលស្ថិតនៅខេត្តសៀមរាប-អង្គរ ញុាំងឲ្យខ្មែរមានស្មារតីចងចាំពីអតីតកាលរបស់ខ្លួន ព្រមទាំងផ្ដល់ក្ដីសង្ឃឹមទៅថ្ងៃអនាគតផង។ ដំណែលដ៏រស់រវើកទាំងនោះឆ្លងកាត់ច្រើនសតវត្សរហូតដល់បង្កើតជាគ្រឹះនៃអត្តសញ្ញាណខ្មែរទាំងមូល។

អង្គរមិនកំណត់ត្រឹមតែជាភូមិសាស្ត្រដែលសម្បូរទៅដោយវត្ថុបុរាណគ្រប់បែបយ៉ាង ដែលមាននៅនោះឡើយ ប៉ុន្តែអង្គរសំដៅទៅលើអារ្យធម៌ដ៏ធំធេងមួយ ដែលលាតសន្ធឹង ហួសឆ្ងាយពីព្រំដែនប្រទេសកម្ពុជានាពេលបច្ចុប្បន្នទៀតផង។ អារ្យធម៌មួយនេះជ្រួតជ្រាបចាក់ឫសគ្រប់ទិដ្ឋភាពនៃសង្គមខ្មែរ។ ក្នុងឧទ្យានអង្គរទាំងមូលមានរបស់៣ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក មិនអាចកាត់ផ្ដាច់ពីគ្នាបានគឺប្រាសាទ បរិស្ថាន និងសហគមន៍មនុស្ស ឬហៅម្យ៉ាងទៀតថាវប្បធម៌ ទេសភាព និងប្រជាជន។





ក្នុងពេលដែលអង្គរត្រូវបានចុះបញ្ជីបេតិកភណ្ឌពិភពលោកមានប្រាសាទស្ថានីយបុរាណវិទ្យានិងប្រវត្តិសាស្ត្រសរុបចំនួន៩១។ តែក្រោយមកទៀត អ្នកបុរាណវិទ្យាបានរកឃើញប្រាសាទ និងស្ថានីយបុរាណរាប់រយទៀត ដែលស្ថិតនៅក្នុងតំបន់អង្គរ តែមិនទាន់មានឈ្មោះនៅក្នុងបញ្ជីនៅឡើយ។ ជាក់ស្ដែងគ្រាន់តែប្រភេទឧបោសថាគារនៅអង្គរធំ ជុំវិញប្រាសាទបាយ័ន និងក្នុងព្រៃមានដល់ទៅជាង១០០ ហើយគ្រឹះប្រាសាទដែលកប់ក្នុងព្រៃក៏មានដល់ទៅរាប់រយទៀត។ ដោយសេចក្ដីស្រឡាញ់ និងគោរព ប្រាសាទបានក្លាយជាដួងព្រលឹងជាតិដែលមិនអាចខ្វះបានរបស់ខ្មែរ។ ជាក់ស្ដែងប្រាសាទអង្គរវត្តត្រូវអ្នកនយោបាយខ្មែរគ្រប់ជំនាន់យកមកធ្វើជានិមិត្តរូបនៃភាពរុងរឿងនៃវប្បធម៌ តាមរយៈទង់ជាតិរបស់ខ្លួន។ នេះក៏ព្រោះតែតម្លៃអង្គរចាក់ស្រេះជ្រៅក្នុងគំនិតមនុស្សខ្មែរហាក់មិនដែលបែកដាច់ពីគ្នាម្ដងណាឡើយ។

បរិស្ថានដែលសំខាន់នៅតំបន់អង្គរ គឺព្រៃឈើ និងទឹក។តាមស្ថិតិជំរឿនព្រៃឈើក្នុងឆ្នាំ២០១៣របស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ព្រៃឈើនៅក្នុងឧទ្យានអង្គរមានប្រមាណជាង៥៧០០ហិកតា គឺស្មើនឹង១៣%នៃផ្ទៃដីក្នុងរមណីយដ្ឋានអង្គរទាំងមូល។ ព្រៃឈើមិនត្រឹមជាប្រភពនៃទឹកភ្លៀងប៉ុណ្ណោះទេ តែមានតួនាទីពិសេសសម្រាប់ប្រាសាទ ធ្វើជារនាំងការពារប្រាសាទ ទប់ទល់នឹងខ្យល់ព្យុះភ្លៀងខ្លាំងដែលបក់បោកមកលើប្រាសាទ និងជាម្ចប់ការពារប្រាសាទទៀតផង។ ជាពិសេសព្រៃឈើប្រៀបដូចជាសម្លៀកបំពាក់ ឬជាអលង្ការ ដែលធ្វើឲ្យប្រាសាទមានភាពរឹងរឹតតែស្រស់បំព្រងថែមទៀត។ ប្រាសាទតាព្រហ្ម គឺជាឧទាហរណ៍ជាក់ស្ដែងមួយ ដែលបាន

ទាក់ទាញទេសចររាប់ពាន់នាក់ចូលទៅទស្សនារៀងរាល់ថ្ងៃ។

ក្រៅពីព្រៃឈើ ទឹកជាបរិស្ថានដ៏សំខាន់មួយទៀតផ្សាភ្ជាប់ខ្លួននឹងអង្គរដែរ។កាលណាគេនិយាយពីអង្គរគេតែងនឹកដល់បារាយណ៍ខាងលិច ដែលហៅថា បារាយណ៍ទឹកថ្លា ដែលមានទំហំ ៨គមx ២.២គម ជាសំណង់នៃវិស្វកម្មធារាសាស្ត្រ ទុកប្រើប្រាស់ជាពិសេសសម្រាប់ការងារកសិកម្មរហូតដល់សព្វថ្ងៃ។ បារាយណ៍ខាងជើង ដែលបានរីងស្ងួតទឹកជាង៥០០ឆ្នាំកន្លងទៅ ក៏ត្រូវបានអាជ្ញាធរជាតិអប្សរាធ្វើការជួសជុលប្រព័ន្ធទឹកបុរាណ បញ្ចូលទឹកពេញ ដែលមានប្រាសាទនាគព័ន្ធនៅចំកណ្តាលគួរឲ្យចង់គយគន់ក្រៃលែង។ ជាពិសេស ទឹកក្នុងកសិណាជុំវិញប្រាសាទនានា ជាប្រភពទឹកផ្ទុកនូវសំណើមជាប្រចាំ ថែរក្សាគ្រឹះប្រាសាទដែលជាខ្សាច់កុំឲ្យស្ងួត ធ្វើឲ្យដួលរលំ ឬទ្រេតប្រាសាទ ។ ក្រៅពីនេះ ប្រព័ន្ធផ្លូវទឹកខ្វាត់ខ្វែង កសិណាទឹក ស្រះបុរាណ ដែលមាននៅក្នុងឧទ្យានអង្គរ ហាក់ដូចជាសរសៃឈាមនៃរាងកាយរបស់មនុស្សយើងដូច្នោះដែរ។ ប្រព័ន្ធធារាសាស្ត្របុរាណក្នុងសម័យអង្គរ មិនត្រឹមតែអាចគ្រប់គ្រងបានយ៉ាងល្អនូវធនធានទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចគ្រប់គ្រងទឹកជំនន់បានទៀតផង។ គេជឿជាក់ថានៅក្នុងសម័យអង្គរដ៏រុងរឿងរាជបុរីមួយនេះប្រាកដជាមានប្រព័ន្ធធារាសាស្ត្រ ដ៏មានប្រសិទ្ធភាពប្រកបដោយភាពស៊ីសង្វាក់គ្នា។ បច្ចុប្បន្ន ប្រព័ន្ធទឹកបុរាណមួយភាគធំត្រូវបានស្តារជួសជុលឡើងវិញ ដែលអាចមិនត្រឹមតែទប់ស្កាត់ទឹកជំនន់ប៉ុណ្ណោះទេ តែថែមទាំងជាប្រភពទឹកសម្រាប់វិស័យកសិកម្មរបស់ប្រជាជនបានគ្រប់រដូវទៀតផង។ ម្យ៉ាងទៀត បណ្តាកសិណាទឹក និងស្រះនានានៃប្រាសាទខ្មែរ សុទ្ធតែមានទំនាក់ទំនងជិតស្និទ្ធនឹងជំនឿសាសនា។ កសិណាទឹកព័ទ្ធជុំវិញប្រាសាទ ត្រូវបានគេជឿជាក់ថាជាតំណាងនៃមហាសាគរដែលនៅព័ទ្ធជុំភ្នំព្រះសុមេរុ ដែលជាទីឋាននៃទេពទាំងឡាយ។ ទន្ទឹមនឹងនេះ ប្រាសាទត្រូវបានសាងសង់ឡើងក្នុងឋានៈជាលំនៅនៃទេព គឺភ្នំព្រះសុមេរុ។ ស្រះខ្លះទៀតជានិមិត្តរូបនៃទន្លេគង្គា និងយមុនាដែលជាទន្លេលាងជម្រះមន្ទិលសៅហ្មង។

តំបន់ជុំវិញប្រាសាទសុទ្ធតែជាភូមិ។ ភូមិក្នុងឧទ្យានអង្គរបច្ចុប្បន្នមាន១១២ភូមិ ២១ឃុំសង្កាត់។ ភូមិទាំងនេះមានប្រជាជនរស់នៅតៗគ្នារាប់ជំនាន់មកហើយ ដែលបានផ្តល់ឲ្យនូវលក្ខណៈពិសេសដល់ឧទ្យានអង្គរឲ្យទៅជាមរតករស់។អ្នកស្រុកទាំងនេះ ត្រូវបានចាត់ទុកជាបេតិកភណ្ឌដែរ ដោយសារអ្នកទាំងនោះបានថែរក្សាបេតិកភណ្ឌអរូបីដែលមាន ទំនៀមទម្លាប់ ប្រពៃណី ពិធីបុណ្យទាន ជំនឿសាសនា ព្រមទាំងសិប្បកម្ម និងរបៀបរស់នៅប្រចាំថ្ងៃ តាំងពីយូរលង់មកហើយ។ ភាសានិយាយក៏ជាមរតកដែរ ដូចជាអ្នកភូមិប្រដាក ភូមិអូរទទឹង ជាដើម មានភាសា និងសំនៀងប្លែកពីគេឯង។ បច្ចុប្បន្នប្រពៃណីមួយចំនួន ដែលអ្នកនៅតំបន់ផ្សេងៗបានបំភ្លេចចោល ឬមិនសូវយកចិត្តទុកដាក់ នៅតែកំពុងបន្តប្រតិបត្តិដោយអ្នកស្រុកអង្គរនៅឡើយ។ ទំនៀមទាំងនោះមានដូចជា ពិធីកោរជុក ពិធីឡើងអ្នកតា ពិធីហៅទឹកភ្លៀង ពិធីហៅព្រលឹង ។ល។

អ្នកស្រាវជ្រាវខ្លះ បានសរសេរថា អង្គរធ្លាប់ត្រូវបានគេបោះបង់ចោលលែងមានមនុស្សរស់នៅ ស្ងាត់ជ្រងំដូចជាព្រៃខ្មោច ហើយទើបតែត្រូវបានរកឃើញឡើងវិញនៅសតវត្សទី១៩។ តាមពិតបើទោះជានៅស.វ.ទី១៥ អង្គរត្រូវបានបោះបង់ចោល ក្នុងឋានៈជារាជធានីក៏មែនពិត ប៉ុន្តែតំបន់នោះ នៅតែមានប្រជាជនរស់នៅជាប់រហូតមកដល់បច្ចុប្បន្ននេះ។ ការតាំងទីដ៏យូរលង់នេះហើយ ដែលធ្វើឲ្យអ្នកអង្គរនៅរក្សាបាននូវទំនៀមទម្លាប់ប្រពៃណីពិសេសៗជាច្រើន ខណៈដែលតំបន់ខ្លះទៀតបានបោះបង់ចោលឬនៅសល់តិចតួច។

ដោយមានការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងមិនដាច់ ពីរាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ និងអនុវត្តផ្ទាល់ដោយឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា បានប្រកាន់ខ្ជាប់នូវគោលការណ៍អភិរក្សតំបន់រមណីយដ្ឋានអង្គរ ឲ្យស្របនឹងទិសដៅ"អភិរក្សដើម្បីអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ដើម្បីអភិរក្ស" ឆ្ពោះទៅរកការរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរ។ក្នុងន័យនេះការរស់នៅជាមួយបេតិកភណ្ឌ គឺមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយ រវាងប្រាសាទ បរិស្ថាន និងសហគមន៍។


ប្រព័ន្ធធារាធ
Angkor Hydra
Tonlé Sgnuot
PREAH KHAN
NEAK PE
ANGKOR THOM
WEST MEBON
TA KEO
Pourk River
PHNOM BAKENG
SRAH SR
TA PROHM
BANTEAY KDEI
Siem Reap River
ANGKOR WAT
PREAH KO
BAKO
PHNOM KROM
Tonlé Sap Lake
©Apsara


សាស្ត្រអង្គរ
aulic Network
BANTEAY SREI
EAN
Phnom Dei
EAST MEBON
PHNOM BOK
Phnom Kulen
RANG
CHAO SREI VIBOL
LOLEI
NG
Roluos River



# ការរស់រានជាថ្មីឡើងវិញ នូវប្រព័ន្ធធារាសាស្ត្រអង្គរ



# ការរស់រានជាថ្មីឡើងវិញ
# នូវប្រព័ន្ធធារាសាស្ត្រអង្គរ

ចក្រភពខ្មែរដែលបានលេចធ្លោឡើងតាមរយៈ សំណង់ស្ថាបត្យកម្ម និងប្រព័ន្ធវិស្វកម្មធារាសាស្ត្រខ្វាត់ខ្វែងជាច្រើន នៅលើទឹកដីអច្ឆរិយអង្គរមានដូចជា បារាយណ៍ កសិណាទឹក ទំនប់សំណង់បង្ហៀរទឹក ដែលធ្វើពីថ្មបាយក្រៀម ស្ពានថ្មបាយក្រៀម អាងទឹក និងប្រឡាយតូចធំនានា។

ដោយឆ្លងកាត់សម័យកាលរាប់សតវត្ស រចនាសម្ព័ន្ធធារាសាស្ត្រតំបន់អង្គរបានប្រឈមនឹងកត្តាមួយចំនួនដូចជា៖ ធម្មជាតិ ការបោះបង់ចោល ដោយមូលហេតុគោករីងស្ងួត និងការកើនឡើងនូវចំនួនប្រជាជន។ បញ្ហាទាំងនេះបានធ្វើឱ្យការគ្រប់គ្រងទឹកនៅក្នុងតំបន់សៀមរាបអង្គរបានក្លាយជាបញ្ហាដ៏ធំមួយចំពោះការងារអភិរក្សប្រាង្គប្រាសាទ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលានូវបញ្ហាប្រឈមទាំងនេះ អាជ្ញាធរអប្សរាកំណត់យកការគ្រប់គ្រងទឹកជាគន្លឹះមួយយ៉ាងសំខាន់ក្នុងការងារអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពតំបន់រមណីយដ្ឋានអង្គរ ។ជាក់ស្តែងអាជ្ញាធរអប្សរាបានគិតគូរឲ្យបានហ្មត់ចត់នូវនយោបាយគ្រប់គ្រងទឹក ដើម្បីបំពេញចំពោះតម្រូវការប្រើប្រាស់ទឹកប្រចាំថ្ងៃទាំងផ្នែកអភិរក្សផង ស្រោចស្រពកសិកម្មផង និង ការរស់នៅរបស់ប្រជាពលរដ្ឋផង។ ដើម្បីសម្រេចបាននូវនយោបាយគ្រប់គ្រងទឹកឲ្យបានល្អប្រសើរ ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណក្នុងឧទ្យានអង្គរគឺជាជម្រើសដ៏ល្អបំផុត។ មិនត្រឹមតែការធ្វើបែបនេះ នាំមកនូវប្រសិទ្ធភាពនៃតួនាទីរបស់ទឹកក្នុងការងារអភិរក្សប្រាង្គប្រាសាទ ការស្រោចស្រពកសិកម្មព្រមទាំងទេសភាពវប្បធម៌និងបរិស្ថានទូទៅក្នុងឧទ្យានអង្គរប៉ុណ្ណោះទេតែក៏បានធ្វើឲ្យប្រព័ន្ធធារាសាស្ត្របានដំណើរការឡើងវិញ ប្រៀបដូចជាដួងព្រលឹងបានត្រឡប់មកវិញផងដែរ។

បើទោះបីការស្តារឡើងវិញជាជម្រើសដ៏ល្អបំផុតក៏ដោយ តែកិច្ចការស្តារឡើងវិញនេះត្រូវការប្រើប្រាស់ពេលវេលាដ៏ច្រើន និងថវិកាសន្ធឹកសន្ធាប់។ ទោះជាយ៉ាងណា អាជ្ញាធរអប្សរា បានសម្រេចជោគជ័យជាស្ថាពរក្នុងការងារជួសជុលឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណនាសម័យអង្គរ ដោយមិនត្រឹមតែអាចគ្រប់គ្រងទឹកបានយ៉ាងមានប្រសិទ្ធភាពបានយ៉ាងល្អប៉ុណ្ណោះទេ តែថែមទាំងអាចគ្រប់គ្រងទឹកជំនន់ក្នុងតំបន់អង្គរនិងទីក្រុងសៀមរាបទៀតផង។ ជាពិសេសទៅទៀតនោះការគ្រប់គ្រងទឹកនេះបានក្លាយជាចំណុចស្នូលមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យកសិកម្មក្នុងស្រុកមួយចំនួននៃខេត្តសៀមរាប ក៏ដូចជាលើកតម្កើងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋតាមវិស័យកសិកម្ម៕





*សំណង់បញ្ចៀសទឹកជំនន់ក្រុងសៀមរាប*

*សំណង់ទំនប់តាសោម កសាងឡើងដើម្បីបញ្ចៀសទឹកជំនន់ក្នុងរមណីយដ្ឋានអង្គរ និង ទីក្រុងសៀមរាប។ ដោយមានការសម្របសម្រួលពីអាជ្ញាធរអប្សរា មានបងប្អូនប្រជាពលរដ្ឋមួយចំនួនក៏បានបរិច្ចាគដីធ្លីរបស់ពួកគាត់ សម្រាប់ផលប្រយោជន៍សហគមន៍ទូទៅ។*





### ទ្វារទឹកបារាយណ៍រាជដាក

ទ្វារទឹកបារាយណ៍រាជដាក (បារាយណ៍ខាងជើង) សម្ព័ន្ធសំណង់បញ្ចៀសទឹកជំនន់។ ក្រៅពីមានតួនាទីសំខាន់ក្នុងការបញ្ចូលទឹកចូលប្រាសាទនាគព័ន្ធ ទ្វារទឹកនេះក៏បានផ្តល់ផលប្រយោជន៍យ៉ាងច្រើនសម្រាប់វិស័យ កសិកម្ម ទេសចរណ៍ និង នេសាទរបស់ប្រជាពលរដ្ឋ៕



សំណង់ទ្វារទឹកអន្ទង់ធ្លូកលើអូរខ្ចូត  សង្កាត់គោកចក ក្រុងសៀមរាប







## ប្រព័ន្ធស្រោចស្រពនៅភូមិគោកត្នោត

សំណង់ប្រព័ន្ធស្រោចស្រពនេះ សាងសង់លើប្រឡាយរំដោះទឹកទៅស្ទឹងពួក ដែលបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋភូមិគោកត្នោត ភូមិគោកបេង ភូមិនគរ-ក្រៅ សង្កាត់គោកចក ក្រុងសៀមរាបនិងភូមិប្រាសាទចារ្យ ឃុំដូនកែវ ស្រុកពួក ។

ប្រព័ន្ធស្រោចស្រពនេះក៏មានទ្វារទឹក ចំនួន៣កន្លែង រួមនឹងការជួសជុលទំនប់ប្រវែង ១៥០ម៉ែត្រ កម្ពស់ ១,៥ម៉ែត្រដើម្បីលើកកម្ពស់ទឹកឲ្យបានគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋសហគមន៍ ៕






៣០ម៉ែត្រ



# ប្រព័ន្ធស្រោចស្រពនៅឃុំប្រដាក

សំណង់បង្ហៀរទឹក ទ្វារទឹក និងប្រឡាយទឹកនៅទំនប់ជៀកស្ថិតក្នុងភូមិអូរទទឹង ឃុំប្រដាក ស្រុកបន្ទាយស្រី។ នេះជាសមិទ្ធផលដ៏វិជ្ជមានដើម្បីឆ្លើយតបសំណើរបស់ប្រជាពលរដ្ឋ និង អាជ្ញាធរឃុំប្រដាក ស្រុកបន្ទាយស្រី ដែលបានស្នើសុំតាមរយៈ ក្រុមការងារសហគមន៍នៃអាជ្ញាធរអប្សរា ឲ្យជួយ សាងសង់ដើម្បីប្រជាពលរដ្ឋមានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ ទាំងផ្នែកខាងលើ និង ផ្នែកខាងក្រោមទំនប់ជៀក។ មិនតែប៉ុណ្ណោះ ប្រឡាយនេះ ថែមទាំងប្រើប្រាស់សម្រាប់បញ្ចូលទឹកទៅកាន់ប្រាសាទបន្ទាយសម្រែផងដែរ៕





## ប្រព័ន្ធស្រោចស្រពនៅភូមិប្រាសាទចារ្យ

សំណង់ប្រព័ន្ធស្រោចស្រពនេះ សាងសង់លើប្រឡាយរំដោះទឹកទៅស្រុកពួក ដែលបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋចំនួន៦ភូមិ គឺភូមិប្រាសាទចារ្យ ភូមិគោកពោធិ៍ ភូមិល្បើក ភូមិពាម ភូមិតាស្នេហ៍ ឃុំដូនកែវ ស្រុកពួក និងភូមិគោកត្នោត សង្កាត់គោកចក ក្រុងសៀមរាប អាចស្រោចស្រពលើផ្ទៃដីជាង១.០០០ហិកតាក្នុងរដូវប្រាំង និង ជាង២.០០០ហិកតាក្នុងរដូវវស្សា។

ក្នុងរដូវប្រាំងប្រព័ន្ធស្រោចស្រពនេះក្លាយជាប្រភពធនធានទឹកយ៉ាងសំខាន់សម្រាប់ឃុំដូនកែវ ដោយទឹកទាំងនោះអាចជួយឲ្យប្រជាពលរដ្ឋដាំដំណាំរួមផ្សំជាច្រើនប្រភេទដើម្បីលក់នៅទីផ្សារនានាក្នុងខេត្តសៀមរាប។

ប្រព័ន្ធស្រោចស្រពនេះមានទ្វារទឹកចំនួន៥កន្លែង រួមនិងទំនប់អមសងខាងប្រវែង១.៣០០ម៉ែត្រ កម្ពស់ ១,៥ម៉ែត្រ ដើម្បីលើកកម្ពស់ទឹកឲ្យបានគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋសហគមន៍ ៕








TOP VIEW
SURFACE IRRIGATE
ANCIENT CANAL
DIKE
DOWN STREAM
UP STREAM
MAIN CANAL
SURFACE IRRIGATE
SURFACE IRRIGATE





ទ្វារទឹកលើខ្នងទំនប់អូរគោងាប់ ឃុំដូនកែវ ស្ថិតក្នុងប្រាសាទចារ្យ ឃុំដូនកែវ ស្រុកពួក



*ទ្វារទឹកលើផ្លូវដើសពីភូមិនគរក្រៅ ទៅសាលាឃុំដូនកែវ ស្ថិតក្នុងប្រាសាទចារ្យ ឃុំដូនកែវ ស្រុកពួក*





*សំណង់ទ្វារទឹក លូជ្រុង លូមូល ស្ថិតលើផ្លូវ១១គម ដែល
ប្រជាពលរដ្ឋឃុំដូនកែវស្នើសុំឲ្យអាជ្ញាធរអប្សរាជួយ
ជួសជុលនោះ បានសម្រេចរួចរាល់ហើយ ដោយឡែក
ការជួសជុលផ្លូវគឺស្ថិតក្នុងគម្រោងឆ្នាំ២០១៦។
សារៈប្រយោជន៍នៃសំណង់ទាំងនេះ គឺដើម្បីរំដោះទឹក
ចេញពីភូមិករអ្នកស្រុកក្នុងរដូវវស្សា និងសម្រាប់
ស្រោចស្រពក្នុងវិស័យកសិកម្ម៕*











# ពង្រីកទំហំទ្វារទឹកអូរតាប្រាក់

ការពង្រីកទំហំទ្វារទឹកបន្ថែមនៅលើប្រឡាយអូរតាប្រាក់ក្នុងភូមិអូរតាប្រាក់ ឃុំពួក ស្រុកពួក ដើម្បីជួយរំដោះទឹកឲ្យបានលឿនការពារទឹកជំនន់។

កាលពីមុនទ្វារទឹកនេះមានទំហំតូចជាងប្រឡាយ ហើយក្នុងពេលមានភ្លៀងធំម្ដងៗ ធ្វើឲ្យទឹកហូរមិនទាន់ បណ្ដាលឲ្យជន់លិចផ្ទះ ផលដំណាំព្រមទាំងទីរួមស្រុកផង។ បច្ចុប្បន្នទ្វារទឹកនេះត្រូវបានពង្រីកឲ្យមានទំហំប៉ុនប្រឡាយ៕





### ទ្វារទឹកថ្មីមួយនៅភូមិព្រៃក្មេង ឃុំខ្នាត ស្រុកពួក

សំណង់ទ្វារទឹកថ្មីស្ថិតក្នុង ភូមិព្រៃក្មេង ឃុំខ្នាត ស្រុកពួក ត្រូវបានអាជ្ញាធរអេបូរា សាងសង់ ឡើង តាមសំណើរបស់ប្រជាពលរដ្ឋនៅភូមិព្រៃក្មេងតាមរយៈក្រុមការងារសហគមន៍អាជ្ញាធរអេបូរា។

ទ្វារទឹកនេះក៏មានតួនាទីជាស្ពានមួយដែលអាចឲ្យប្រជពលរដ្ឋក្នុងភូមិ ធ្វើដំណើរឆ្លងកាត់បានងាយស្រួលជាងមុន។ ក្នុងរដូវវស្សា ទឹកអាចរំដោះចេញតាមទ្វារទឹកមួយនេះ ដើម្បីបញ្ចៀសការលិចលង់ដល់ផ្ទះសម្បែងប្រជាពលរដ្ឋ៕





ប្រឡាយពេលស្តារហើយ



ប្រឡាយមុនពេលស្តារ



កំពុងស្តារ

## ស្តារប្រឡាយផ្គត់ផ្គង់ទឹក

ប្រឡាយមួយខ្សែប្រវែង៧.០០០ម៉ែត្រស្ថិតក្នុងភូមិខ្នាត ឃុំខ្នាត ស្រុកពួក ត្រូវបានអាជ្ញាធរអប្សរា ស្តារឡើងវិញតាមសំណូមពររបស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។ ប្រឡាយនេះមានសារៈសំខាន់ដើម្បីប្រជាពលរដ្ឋមានទឹកគ្រប់គ្រាន់សម្រាប់បង្កបង្កើនផលពិសេសការធ្វើស្រែប្រាំងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំខ្នាត និង រហូតឃុំកែវពណ៌ស្រុកពួក៕



# ការងារគ្រប់គ្រងស្រោចស្រពបារាយណ៍ខាងលិច

បារាយណ៍ខាងលិចត្រូវបានរាជរដ្ឋាភិបាលប្រគល់ជូនមកអាជ្ញាធរអប្សរាគ្រប់គ្រងកាលពីខែកក្កដា ឆ្នាំ២០១៤។

បារាយណ៍ខាងលិចត្រូវបានបុព្វបុរសខ្មែរ កសាងឡើងក្នុងសតវត្សទី១១ មានទទឹងប្រវែង ២,២គីឡូម៉ែត្រ និង បណ្តោយប្រវែង ៨គីឡូម៉ែត្រ កសាងឡើងក្នុងគោលបំណងរក្សាទឹកដើម្បីស្រោចស្រពដំណាំកសិកម្ម បារាយណ៍ខាងលិចក៏ធ្លាប់បានស្តារនិងជួសជុលឡើងវិញនាអំឡុងទសវត្ស ឆ្នាំ១៩៣០ និង ១៩៥០។ បច្ចុប្បន្នបារាយណ៍ខាងលិចមានលទ្ធភាពប្រមូលរក្សាទឹកក្នុងកម្រិតអតិបរិមា ប្រមាណ ៥៦លានម៉ែត្រគូប ។ បរិមាណទឹកដ៏ច្រើនសន្ធឹកសន្ធាប់នេះត្រូវបានអាជ្ញាធរអប្សរា ប្រើប្រាស់ក្នុងវិស័យអភិរក្សប្រាសាទ ស្រោចស្រពដំណាំកសិកម្មជូនប្រជាពលរដ្ឋចំនួន ១៣.០០០ហិចតា និង ដើម្បីផ្គត់ផ្គង់ជា ទឹកស្អាតសម្រាប់ផ្គត់ផ្គង់ទីក្រុងសៀមរាប។

អាជ្ញាធរអប្សរាបានគ្រប់គ្រងទ្វារទឹកបារាយណ៍ទឹកខាងលិច ដោយការទទួលខុសត្រូវខ្ពស់លើតម្រូវការប្រើប្រាស់ទឹកសម្រាប់ការងារបង្កបង្កើនផលរបស់ប្រជាកសិករដែលធ្លាប់តែពឹងផ្អែកលើប្រភពទឹកបារាយណ៍ខាងលិច និងធានាឲ្យបានក្នុងការបញ្ចៀសមហន្តរាយដែលគំរាមកំហែងតំបន់អង្គរ ទីក្រុងសៀមរាប ។

នៅឆ្នាំ២០១៥ អាជ្ញាធរអប្សរាបានបំពាក់ទ្វារទឹកថ្មីចំនួន០៤ និងប្តូរប្រអប់មេកានិចថ្មីចំនួន២៤ប្រអប់របស់ប្រព័ន្ធស្រោចស្រពបារាយណ៍ខាងលិចសំដៅពង្រឹង និង ធានាឲ្យបាននូវសុវត្ថិភាព ធានាបានដល់ការផ្គត់ផ្គង់ទឹកបានគ្រប់គ្រាន់៕



សំណង់ទ្វារទឹកបារាយណ៍ខាងលិច (មើលពីមុខ) សំណង់នេះមានតួនាទីសំខាន់ក្នុងការរការ បញ្ឈាល់ទឹកទុកក្នុងបារាយណ៍ និងបង្ហូរទឹកស្រោចស្រពនៅរដូវប្រាំង



ប្រឡាយមេ(ស្ទឹង) ចេញពីទ្
មានតួនាទីចែកចាយទឹកទៅកាន់ប្រឡាយរ
ប្រើប្រាស់បង្ហូរទឹកស្រោចស្រពផ្ទៃដីកសិកម្
លើប្រភពទឹកបារ



សំណង់ទ្វារទឹកលើប្រឡាយរងលេខ៤ (ជួសជុលមេកានិច)



សំណង់ទ្វារទឹកលើប្រឡាយរងលេខ៣(ជួសជុលមេកានិច)



ារទឹកបារាយណ៍ខាងលិច
ងទាំងប្រាំបីទៀតដែលអាជ្ញាធរជាតិអប្សរា
ូរបស់បងប្អូនប្រជាពលរដ្ឋដែលពឹងផ្អែក
រាយខាងលិច។



សំណង់ទ្វារទឹកលើប្រឡាយរងលេខ៤ (ជួសជុលមេកានិច)

# សហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ខាងលិច ចូលរួមសម្អាតប្រឡាយ

ប្រជាពលរដ្ឋជាង៨០០នាក់មកពី៤ឃុំសង្កាត់ បានចូលរួមជាមួយអាជ្ញាធរអប្សរាធ្វើការសម្អាតប្រព័ន្ធប្រឡាយបង្ហូរទឹកចេញពីបារាយណ៍ខាងលិច ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ប្រជាសមាគមកសិករប្រើប្រាស់ទឹកបារាយ-ណ៍ខាងលិចចំនួន៩ឃុំសង្កាត់ក្នុងក្រុងសៀមរាប និងស្រុកពួកប្រើប្រាស់ក្នុងវិស័យកសិកម្ម។

អាជ្ញាធរអប្សរាបានជួយស្តារ និងកាយប្រឡាយចាស់ៗមួយចំនួននៃប្រព័ន្ធស្រោចស្រពបារាយខាងលិច ឲ្យដំណើរការប្រើប្រាស់បាន។ការចូលរួមសម្អាតប្រឡាយនៅពេលនេះគឺមានការចូលរួមពីប្រជាពលរដ្ឋដ៏ច្រើន ដែលបង្ហាញឲ្យកាន់តែច្បាស់ថា ប្រជាពលរដ្ឋបានយល់ច្បាស់ពីការងាររបស់អាជ្ញាធរអប្សរា ក្នុងការថែទាំប្រព័ន្ធប្រឡាយមេ ជានាការប្រើប្រាស់យូរអង្វែង ក៏ដូចជាបំពេញតម្រូវការជាក់ស្តែងសម្រាប់ការងារបង្កបង្កើនផលនារដូវប្រាំង លើផ្ទៃដីចំនួន៤ពាន់ហិកតា។



ចាប់តាំងពីអាជ្ញាធរអប្សរាបានទទួលការគ្រប់គ្រងប្រព័ន្ធទឹកនៅបារាយណ៍ខាងលិចមក កសិករយើងមានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់បង្កបង្កើនផល មិនមានការបារម្ភពីកង្វះខាតទឹកនោះទេ។ ប្រជាពលរដ្ឋដែលជាស-មាជិកសហគមន៍ប្រើប្រាស់ទឹកបារាយណ៍ខាងលិច បានសម្តែងសេចក្តីរីករាយផងដែរ ចាប់ពីអាជ្ញាធរជាតិអប្សរាទទួលបានគោលការណ៍គ្រប់គ្រងទឹក និងទ្វារទឹកនៅបារាយណ៍ខាងលិចពីរាជរដ្ឋាភិបាលរយៈពេលជាង១ឆ្នាំកន្លងមកនេះមានការសហការគ្នាបានល្អណាស់ ជាមួយសហគមន៍ប្រើប្រាស់ទឹកបារាយណ៍ខាងលិច។ ក្រុមការងាររបស់អាជ្ញាធរអប្សរាបានជួបពិភាក្សាជាមួយសហគមន៍ប្រើប្រាស់ ទឹកបារាយ-ណ៍ខាងលិចជាញឹកញាប់ ដើម្បីស្វែងយល់អំពីតម្រូវការរបស់ពួកគាត់ និងផែនការដែលត្រូវធ្វើបន្ថែមទៀត។

ការចូលរួមសម្អាតប្រឡាយរបស់ប្រជាកសិករក្នុងពេលនេះ គឺជាការបញ្ជាក់ពីការគាំទ្រ ចំពោះអាជ្ញាធរអប្សរាដែលបានរៀបចំប្រព័ន្ធធារាសាស្ត្របុរាណនាសម័យអង្គរឲ្យដំណើរការឡើងវិញ ដែលសកម្មភាពនេះ មិនត្រឹមតែចូលរួមក្នុងកិច្ចការអភិរក្សប្រាង្គប្រាសាទ ការបញ្ចៀសទឹកជំនន់តំបន់អង្គរ និងទីក្រុងសៀមរាបប៉ុណ្ណោះទេ តែថែមទាំងបានក្លាយជាប្រភពទឹកយ៉ាងសំខាន់ ដល់បងប្អូនប្រជា-ពលរដ្ឋសម្រាប់ការងារកសិកម្មទៀតផង។









សូមបញ្ជាក់ថា កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលបានប្រគល់ការងារគ្រប់គ្រងទឹក និងទ្វារទឹក នៅបារាយណ៍ខាងលិច ជូនអាជ្ញាធរអប្សរា ដោយត្រូវទទួលខុសត្រូវទាំងស្រុងលើតម្រូវការទឹកសម្រាប់ស្រូវចំនួន ១២.០០០ហិកតា (ស្រូវវស្សា៨.០០០ហិកតា ស្រូវប្រាំង ៤.០០០ហិកតា) និងដំណាំរួមផ្សំផ្សេងទៀតចំនួន១.០០០ ហិកតា និងធានាដោះស្រាយរាល់បញ្ហាគ្រោះទឹកជំនន់ និងភាពរាំងស្ងួត ដែលអាចកើតមានឡើងជាយថាហេតុ។ បន្ទាប់ពីបានទទួលគោលការណ៍នេះហើយ អាជ្ញាធរអប្សរា បានជួសជុល ស្ដារឡើងវិញជាបន្ទាន់នូវទ្វារទឹក និងប្រព័ន្ធប្រឡាយនៃបារាយណ៍ខាងលិច ដែលការងារនេះ ធ្វើឲ្យប្រជាពលរដ្ឋមានទឹកគ្រប់គ្រាន់សម្រាប់ការបង្កបង្កើនផលបានគ្រប់រដូវ៕

# ហេដ្ឋារចនាសម្ព័នផ្លូវថ្នល់

កិច្ចការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ស្ពាន ផ្លូវថ្នល់ លូទឹក ប្រឡាយទឹក ស្ថិតនៅក្នុងមុំអាទិភាពយ៉ាងសំខាន់មួយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នៃរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។ ស្របតាមទស្សនវិស័យនេះ អាជ្ញាធរអប្សរា តាមរយៈក្រុមការងារសហគមន៍ បានយក ចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញឲ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនៅនឹងកន្លែងជាពិសេសតំបន់ដែលស្ថិតក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ។

ដាក់ស្តែងដោយពិនិត្យឃើញភាពចាំបាច់និងតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់បងប្អូនប្រជាពលរដ្ឋ អាជ្ញាធរជាតិអប្សរាបានកសាងផ្លូវថ្នល់ ស្ពាន លូទឹក ប្រឡាយទឹក តូចធំជាច្រើនកន្លែង។ រាល់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បានបង្កើតជាឱកាសដ៏ល្អប្រសើរសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋាអង្គរ ដើម្បីទទួលផលប្រយោជន៍ពីការរីកចម្រើននៃវិស័យទេសចរណ៍ហើយអាចធ្វើដំណើរ និងការប្រាស្រ័យទាក់ទងរវាងសហគមន៍ប្រជាពលរដ្ឋកាន់តែល្អប្រសើរ ដែលកត្តាទាំងនេះបាននាំមកនូវលទ្ធភាពជាច្រើនជូនប្រជាពលរដ្ឋ ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់។ ប្រជាពលរដ្ឋអាចស្វែងរកឱកាសក្នុងការពង្រីកមុខរបរ និងជំនួញដោយសមរម្យព្រមទាំងអាចដឹកជញ្ជូនផលិតផល កសិកម្មធម្មជាតិ សិប្បកម្មរបស់ខ្លួនមកផ្គត់ផ្គង់ទីផ្សារដល់ភ្ញៀវទេសចរ។







ស្ពានបេតុងប្រវែង ២៨ម៉ែត្រ ទទឹង ៥ម៉ែត្រ
កសាងឡើងក្នុង ភូមិបង្កោង សង្កាត់អំពិល ក្រុងសៀមរាប ខេត្តសៀមរាប
ដើមឡើយទីនេះមានស្ពានឈើចាស់ទ្រុឌទ្រោមខ្លាំងមួយ ដែលសូម្បីតែម៉ូតូក៏លំបាកក្នុងការឆ្លងកាត់ផង ។
ការសាងសង់ស្ពានថ្មីនេះបានក្លាយជាប្រយោជន៍យ៉ាងសំខាន់ដល់ការដឹកជញ្ជូនភោគផលដំណាំ
របស់បងប្អូនប្រជាពលរដ្ឋពីភូមិបង្កោង ទៅកាន់ទីផ្សារកាត់តាមស្ទឹងរលួសបានកាន់តែងាយស្រួល៕





ស្ពានចាស់





ស្ពានបេតុងប្រវែង២៤ម៉ែត្រ ទទឹង៥ម៉ែត្រជាសំណើសុំរបស់ប្រជាពលរដ្ឋក្នុងភូមិត្រាចឃុំបល្ល័ង្គស្រុកប្រាសាទបាគងខេត្តសៀមរាប ស្ពាននេះសាងសង់ឡើងដើម្បីបញ្ចៀសការធ្វើដំណើរដោយរថយន្តធំៗ ដែលធ្វើដំណើរ ដោយឆ្លងតាមស្ពានថ្មបុរាណ ទៅផ្លូវជាតិលេខ៦៧ ដោយប្រើស្ពានថ្មីជំនួសវិញ ក្នុងការដឹក ជញ្ជូនកសិផល របស់ប្រជាពលរដ្ឋ ហើយរក្សាអភិរក្សស្ពានបុរាណ ។





ស្ពានបេតុង បណ្តោយ២០ម និងទទឹង ៣,៥ម ស្ថិតក្នុងភូមិដូនទ្រ ឃុំល្វា ស្រុកពួក
សាងសង់នៅលើប្រឡាយអូរតាប្រាក់ ភ្ជាប់ពីស្រែសហមគមន៍ របស់ប្រជាពលរដ្ឋ ទៅផ្លូវលំភូមិដូនទ្រ
ស្រុកពួក និង ផ្លូវជាតិលេខ៦។ ស្ពាននេះបម្រើផលប្រយោជន៍ អ្នកភូមិក្នុង ឃុំល្វា ក្នុងការដឹក កសិផលស្រែចម្ការ ដូចជា
ភូមិដូនទ្រ ភូមិគោកស្រម៉ ភូមិព្រះអង្គទ្រង់ ជាដើម។





## ស្ពានឆ្លងទៅ
## មណ្ឌលសុខភាពភូមិបង្កោង

ស្ពានដែកបេឡេ សាងសង់ជូនប្រជាពលរដ្ឋភូមិបង្កោង សង្កាត់អំពិល ក្រុងសៀមរាប ដើម្បីសម្រួលការធ្វើដំណើររបស់បងប្អូនដែលត្រូវការមកមណ្ឌលសុភាពភូមិបង្កោង ជាពិសេសស្ត្រីដែលពពោះត្រូវមកសម្រាលកូននៅមណ្ឌលសុខភាព។ អាជ្ញាធរអប្សរាបានការសម្រេចសាងសង់ស្ពានបេឡេជំនួសស្ពានឈើចាស់ដែលទ្រុឌទ្រោមខ្លាំង ហើយស្ពានបង្កោងនេះបានភ្ជាប់ទំនាក់ទំនងរវាងភូមិតាកុយនិងភូមិបង្កោងក្នុងការប្រកបរបរផ្សេងៗផងដែរ។





## ស្ពានភ្ជាប់ទំនាក់ទំនង
## ភូមិពាម និង ភូមិតាស្នេហ៍

ស្ពានបេតុងទទឹង៣,៥ម៉ែត្រ និងបណ្ដោយ២៥ម៉ែត្រ ជាសំណូមពររបស់ប្រជាពលរដ្ឋ ភូមិពាម និង ភូមិតាស្នេហ៍ ឃុំដូនកែវស្រុកពួក តាមរយៈក្រុមការងារសហគមន៍បានសាងសង់រួចរាល់ក្នុងឆ្នាំ២០១៥ ។ ស្ពានបេតុងនេះស្ថិតនៅខាងជើងទំនប់បារាយណ៍ទឹកថ្លា ដែលពីមុនជាស្ពានឈើមានសភាពចាស់ទ្រុឌទ្រោម ហើយប្រជាពលរដ្ឋនៅភូមិទាំង២ខាងលើមានការលំបាក ក្នុងការធ្វើដំណើរឆ្លងកាត់ ទើបស្នើសុំឲ្យអាជ្ញាធរអប្សរាជួយជួសជុល ។ ដោយមើលឃើញពីភាពលំបាកនេះ អាជ្ញាធរអប្សរាបានសម្រេចសាងសង់ជាស្ពានបេតុងជំនួសស្ពានឈើចាស់ ដើម្បីជានាការប្រើប្រាស់បានយូរអង្វែង ។





ផ្លូវ៦០ ជាប្រភេទផ្លូវក្រោះមានប្រឡាយអមសងខាង សាងសង់រួចរាល់នៅក្នុងឆ្នាំ២០០៣ មានប្រវែង១០គីឡូម៉ែត្រ លាតសន្ធឹងពីត្បូងទៅជើងត្រង់ចំណុចផ្លូវជាតិលេខ៦ (ខាងកើតផ្សារលើ) មកទល់នឹងផ្លូវវង់តូចចូលរមណីយដ្ឋានអង្គរ និងពីលិចមកកើតត្រង់ចំណុចមុខមន្ទីរពេទ្យគន្ធបុប្ផាមកទល់នឹងចំណុចផ្លូវបំបែកត្រាំនាគ។






កំណាត់ផ្លូវ៦០ មានប្រវែង៩.៦៧៩ម៉ែត្រ សាងសង់ស្របផ្លូវជាតិលេខ៦ ពីលិចទៅកើតត្រង់ចំណុចបំបែកផ្លូវត្រាំនាគ មកទល់នឹងផ្លូវកៅស៊ូបុរីវដ្តបាល ។ ផ្លូវនេះមានសារៈសំខាន់យ៉ាងខ្លាំងក្នុងបញ្ចៀសការកកស្ទះ និងគ្រោះថ្នាក់ចរាចរ-ណ៍នៅតាមដងផ្លូវជាតិ លេខ៦ ជាពិសេសនោះគឺបានជួយកាត់បន្ថយពេលវេលាក្នុងការធ្វើដំណើរពីទីក្រុងសៀមរាប មកស្រុកប្រាសាទបាគង និងស្រុកបន្ទាយស្រី។


60








## ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ

-សាងសង់: ២០០៩-២០១២

-ប្រវែង: ៣៤,៥គីឡូម៉ែត្រ

-ចំណុចឆ្លងកាត់: សង្កាត់សៀមរាប សង្កាត់គោកចក ឃុំនគគ្រោ ស្រុកអង្គរធំ ស្រុកបន្ទាយស្រី

-សារៈប្រយោជន៍: បញ្ចៀសរថយន្តធំៗពីរមណីយដ្ឋានអង្គរ និង ដឹកជញ្ជូនកសិផល។








ស្វាយចេក
Svay Chek
ភ្នំបូក
Phnom Bok





## ផ្លូវបេតុងនៅផ្សារគោកស្នួល

ផ្លូវបេតុងមួយខ្សែប្រវែង៩៣០ម៉ែត្រត្រង់ផ្សារគោកស្នួល ភ្ជាប់ពីផ្លូវជាតិលេខ៦ ចូលទៅភូមិប្រឡាយ ឃុំខ្នាត ស្រុកពួក ត្រូវបានអាជ្ញាធរអប្សរាសាងសង់ជូនប្រជាពលរដ្ឋដើម្បីសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនកសិផលផ្សេងៗ ។ ផ្លូវមួយខ្សែនេះជាសំណូមពររបស់ប្រជាពលរដ្ឋភូមិប្រឡាយ ឃុំខ្នាត ដែលបានស្នើសុំមកអាជ្ញាធរអប្សរា ឲ្យជួយជួសជុលផ្លូវក្រាលគ្រួសក្រហម ប៉ុន្តែដោយមើលឃើញថាដើម្បីធានាការធ្វើដំណើរ និងប្រើប្រាស់បានយូរផងនេះ ទើបអាជ្ញាធរអប្សរាបានឯកភាពជាមួយអាជ្ញាធរមូលដ្ឋានសាងសង់ជាផ្លូវបេតុងជូនតែម្តង ៕



## ផ្លូវពីភូមិបង្កោងទៅផ្លូវជាតិលេខ២៦៧

ផ្លូវក្រាលគ្រួសក្រហមប្រវែង៣គីឡូម៉ែត្រ ចាប់ពីចំណុចក្បាលស្ពានបេឡេក្នុងភូមិបង្កោង សង្កាត់អំពិលក្រុងសៀមរាប ដល់ផ្លូវជាតិលេខ២៦៧ក្នុងភូមិតាកុយ ឃុំបល្ល័ង ស្រុកប្រាសាទបាគង។ ផ្លូវនេះដើមឡើយជាផ្លូវដីសដែលពិបាកក្នុងការធ្វើដំណើរយ៉ាងខ្លាំងព្រោះមានដីផុសនៅរដូវប្រាំង និងរអិលខ្លាំងក្នុងរដូវវស្សា ៕





មុនជួសជុល



ជួសជុលរួចរាល់

## ការងារលើកស្ទួយផ្លូវ និងស្ពានប្រឡាយនៅភូមិលាងដៃ

ផ្លូវក្រាលគ្រួសក្រហមប្រវែង ១.៦០០ម៉ែត្រ ទទឹង ៥ម៉ែត្រ នៅឃុំលាងដៃ ស្រុកអង្គរធំ ត្រូវបានសាងសង់ឡើងចេញពីភូមិលាងដៃមកទល់នឹងផ្លូវវង់ធំត្រង់ចំណុចខាងកើតប្រាសាទព្រះខ័ន ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋនិងគ្រួសារនៅក្នុង ភូមិលាងដៃ ភូមិដូនឪ ភូមិតាប្រុក ភូមិសម្រោង និង ភូមិភ្នំ។ ម្យ៉ាងវិញទៀតផ្លូវមួយខ្សែនេះក៏បានជួយសម្រួលដល់ការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋក៏ដូចជាការដឹកជញ្ជូនភ្ញៀវទេសចរ និងផលិតផលកសិកម្មផ្សេងៗទៅកាន់ទីផ្សារ។


50.10
50.00
m=1:1.5
48.00
48.60
48.50
500
4000
6000
m=1:1.5
47.50
ROAD AT LEANG DAI VILLAGE
DEPARTMENT OF WATER MANAGEMENT
CROSS SECTION
SCALE:
DESCRIPTION
DATE



សាងសង់ផ្លូវលំដីសនៅលើខ្នងទំនប់អូរតាប្រាក់ប្រវែង៣គីឡូម៉ែត្រ ដើម្បីជួយសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋសហគមន៍នៅតាមប្រឡាយនេះមានឃុំដូនកែវ និងឃុំពួក ស្រុកពួក ។ ផ្លូវនេះក៏សម្រាប់ប្រើជាទំនប់ការពារស្រុកពួកពីទឹកជំនន់ផងដែរ។





សាងសង់ផ្លូវដើសប្រវែង៤.០០០ម៉ែត្រ អមសងខាងស្ទឹងព្រះស្រុក ស្ថិតក្នុងភូមិស្ទឹងព្រះស្រុក ឃុំល្វា ស្រុកពួក។



# អាជ្ញាធរជាតិអប្សរាចូលរួមក



# ារងារសង្គម



# ក្រុមការងារសហគមន៍
# របស់អាជ្ញាធរអប្សរា

ក្រុមការងារសហគមន៍ជាក្រុមការងារផ្សព្វផ្សាយចល័តរបស់អាជ្ញាធរអប្សរា ដែលបានចុះដល់១១២ភូមិស្ថិតក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ និងតំបន់ពាក់ព័ន្ធជាដើម។ ក្រុមការងារសហគមន៍មានតួនាទី និងភារកិច្ច ចុះផ្សព្វផ្សាយជូនប្រជាពលរដ្ឋយល់ដឹងអំពីបេសកកម្មរបស់អាជ្ញាធរអប្សរាក្នុងការគ្រប់គ្រងថែរក្សាការពារ និងអភិរក្សតំបន់រមណីយដ្ឋានអង្គរ ពន្យល់ពីច្បាប់ស្តីពីកិច្ចការការពារបេតិកភណ្ឌបទដ្ឋាននៃការសាងសង់ និងការប្រើប្រាស់ដីធ្លីក្នុងតំបន់អង្គរ កិច្ចការអភិរក្សបេតិកភណ្ឌអរូបី។

រាល់ការផ្សព្វផ្សាយ មានគោលបំណងទប់ស្កាត់ការរីករាលដាលសំណង់អនាធិបតេយ្យ និងការប្រើប្រាស់ដីធ្លីពុំសមស្របនៅក្នុងរមណីយដ្ឋានអង្គរ ធ្វើយ៉ាងណាសំដៅឲ្យប្រជាពលរដ្ឋយល់ដឹង ស្រឡាញ់ និងចូលរួមក្នុងការថែរក្សាការពារ និងអភិរក្សរមណីយដ្ឋានអង្គរ ក៏ដូចជាការពារ និងអភិរក្សព្រៃឈើ ដើម្បីទុកជាមរតកដល់កូនចៅខ្មែរជំនាន់ក្រោយទៀត។

ជាមួយគ្នានេះដែរក្រុមការងារសហគមន៍បានដើរតួជាអ្នកផ្តល់សេវាបម្រើជូនប្រជាពលរដ្ឋដល់ទីកន្លែងលើករណីស្នើសុំជួសជុលដូចជាសង់ទ្រុងមាន់ ទ្រុងទា ក្រោលគោ ជង្រុកស្រូវ បង្គន់អនាម័យ ជួសជុលជញ្ជាំងផ្ទះ ដំបូលផ្ទះ ជណ្តើរ ប្តូរសសរ តសំយាប កតដ្ឋក្រោមផ្ទះ ។ល។ ដោយប្រជាពលរដ្ឋពុំចាំបាច់ចំណាយពេលវេលា និងមធ្យោបាយធ្វើដំណើរមកដល់ទីស្នាក់ការអាជ្ញាធរអប្សរានោះទេ ។ ជាងនេះទៅទៀតក្រុមការងារសហគមន៍ក៏បានទទួលយកនូវសំណើ និងសំណូមពររួមរបស់ប្រជាពលរដ្ឋដូចជាការស្នើសុំជួសជុលផ្លូវ សង់ស្ពាន ទ្វារទឹក អណ្តូងទឹក ដាក់លូ ស្តារប្រឡាយ សុំកូនឈើជាដើម។ ហើយសំណើទាំងនេះក្រុមការងារសហគមន៍ ក៏បានសុំសហការជាមួយនាយកដ្ឋានពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា នឹងសម្រេចជូនប្រជាពលរដ្ឋជាបន្តបន្ទាប់។

ក្រុមការងារសហគមន៍បានធ្វើការងារយ៉ាងសស្រាក់សស្រាំ រៀងរាល់សប្តាហ៍ដោយចុះដល់មូលដ្ឋានផ្ទាល់ដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋសហគមន៍ ពិនិត្យដោះស្រាយរាល់សំណើផ្សេងៗ ជាពិសេសការចុះសាកសួរសុខទុក្ខបងប្អូនស្ត្រីទើបសម្រាលកូនក្នុងឧទ្យានអង្គរ និងនាំយកអំណោយរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា និងលោកជំទាវ មានសម្ភារៈកញ្ចប់ទ្រទ្រង់សុខភាពម្តាយ និងទារក(ឃីត) និងថវិកាមួយចំនួនផងដែរ ។

ក្រៅតែពីការអនុញ្ញាតឲ្យមានការជួសជុលដូចខាងលើ អាជ្ញាធរអប្សរាក៏បានផ្តល់ផ្លូវថ្នល់ ស្ពាន លូ ទ្វារទឹក ប្រឡាយទឹក ចូលរួមឧបត្ថម្ភប្រជាពលរដ្ឋរងគ្រោះដោយគ្រោះធម្មជាតិ ឧបត្ថម្ភជនពិការ ចាស់ជរា និងការចូលរួមក្នុងពិធីបុណ្យសាសនាក្នុងតំបន់រមណីយដ្ឋានអង្គរជាច្រើនផងដែរ ។













## សកម្មភាពចែកសម្ភារៈទ្រទ្រង់សុខភាពម្តាយ និងទារក ក្នុ
## របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួ





ងតំបន់រមណីយដ្ឋានអង្គរក្រោមគំនិតផ្តួចផ្តើម និង ថវិកាផ្ទាល់
លបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា និង លោកជំទាវ













# អាជ្ញាធរអប្សរាលើកតម្លៃអ្នកស្រុកអង្គរ តាមរយៈការទំនុកបម្រុងអ្នកមានទេពកោសល្យ

ការអភិវឌ្ឍឧទ្យានអង្គរចាំបាច់ត្រូវការធនធានមនុស្សដែលជាកម្លាំងចលករយ៉ាងសំខាន់ ការបណ្តុះបណ្តាលក្មេងៗជំនាន់ក្រោយឲ្យមានសមត្ថភាពក្នុងការអភិវឌ្ឍសង្គមជាតិ និងសង្គមគ្រួសារជាការងារមួយដ៏ចាំបាច់បំផុត។ អាជ្ញាធរអប្សរា មានទិសដៅយ៉ាងជាក់លាក់ក្នុងការងារអភិរក្ស និងអភិវឌ្ឍន៍ តំបន់រមណីដ្ឋានអង្គរ ឈរលើគោលការណ៍ "ប្រាសាទ ព្រៃឈើ និងអ្នកស្រុក" ការលើកតម្លៃនៃអ្នកស្រុកអង្គរ អាជ្ញាធរអប្សរា បានយកចិត្តទុកដាក់ជាខ្លាំង លើការងារបណ្តុះបណ្តាលជំនាញជូន បងប្អូនដែលត្រូវការក្នុងការប្រកបរបរ កសិកម្ម សិប្បកម្ម ជាដើម។

ក្រោយទទួលព័ត៌មានថាកុមារីដែលជាអ្នកស្រុកអង្គរមានទេពកោសល្យផ្នែកគូរគំនូរដ៏អស្ចារ្យទើបអាជ្ញាធរអប្សរា ដោយមានឯកឧត្តម សុខ សង្វារ អគ្គនាយករង និងក្រុមការងារនៃអាជ្ញាធរអប្សរា បានទៅជួបក្រុមគ្រួសាររបស់ ស្រីណុច ហើយបានជួយឧបត្ថម្ភជាបន្តបន្ទាប់ ទាំងសម្ភារៈសិក្សា និង ទំនាក់ទំនងសប្បុរសជន ស្វែងរកអាហារូបករណ៍ ក្នុងការជំរុញបណ្តុះបណ្តាលដល់ក្មេងស្រីដ៏មានទេពកោសល្យចេញពីកូនចៅអ្នកស្រុកអង្គរ។

សព្វថ្ងៃស្រីណុចកំពុងរៀនថ្នាក់ទី២ទាំងភាសាខ្មែរ និងភាសាបរទេស នៅសាលាអន្តរជាតិ ហ្គោ គ្លូប៊ល។ សាលាបានឯកភាពផ្តល់អាហារូបករណ៍ដល់ស្រីណុច សម្រាប់ថ្នាក់សិក្សាពេញម៉ោង ទាំងចំណេះដឹងទូទៅ និងភាសាបរទេស រហូតដល់ចប់ថ្នាក់ទី១២ បូករួមនឹងការផ្តល់សំលៀកបំពាក់ សម្ភារៈសិក្សា និងអាហារថ្ងៃត្រង់។ លើសពីនេះ សាលាក៏បានទទួលលោកឪពុករបស់ស្រីណុចឲ្យចូលបម្រើការងារផងដែរ។

ក្តីរំពឹងទុករបស់អាជ្ញាធរអប្សរាដែលបានខំប្រឹងប្រែងជ្រោមជ្រែងកុលបុត្រកុលធីតាដែលមានឈាមជ័រជាអ្នកស្រុកអង្គរ គឺចង់ឲ្យអ្នកដែលទទួលការបណ្តុះបណ្តាលហើយ សូមយកចំណេះដែលខ្លួនមានមកបម្រើដល់សង្គមជាតិ និងចូលរួមអភិវឌ្ឍន៍តំបន់អង្គរ ពោរពេញដោយសេចក្តីថ្លៃថ្នូរផូផង់។ យើងក៏ចូលរួមអបអរ ហើយសម្លឹងចាំមើលអនាគតដ៏ភ្លឺស្វាងរបស់ ស្រីណុច នៅពេលរៀនចប់ ៕



អាជ្ញាធរអប្សរាជូនស្រីណុច ទៅចុះឈ្មោះចូលរៀននៅសាលាអន្តរជាតិ ហ្គោ គ្លូប៊ល



អាជ្ញាធរអប្សរាឧបត្ថម សម្ភារៈសិក្សា កង់ ម៉ូតូ និង អាហារូបករណ៍សម្រាប់ការសិក្សា១២ឆ្នាំ នៅសាលាអន្តរជាតិ ជូនដល់ស្រីណុច និងគ្រួសារ

## អាជ្ញាធរអប្សរាផ្ដល់អាជីពការងារដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរ



ទន្ទឹមនឹងការអភិរក្សបេតិកភណ្ឌដ៏មានតម្លៃរបស់ដូនតា អាជ្ញាធរអប្សរាក៏តែងយកចិត្តដាក់ជាប្រចាំចំពោះជីវភាពនៅរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរផងដែរ។

ក្នុងបេសកកម្មលើកស្ទួយជីវភាពនេះ អាជ្ញាធរអប្សរាបានបង្កើតមុខរបរជូនប្រជាពលរដ្ឋធ្វើដើម្បីទាញបាននូវអត្ថប្រយោជន៍ពីវិស័យទេសចរណ៍។

ក្រៅពីនេះ មានអ្នកអង្គរមិនតិចទេ ដែលអាជ្ញាធរអប្សរាបានផ្ដល់ការងារតាមរយៈ ការងារជាភ្នាក់ងារសណ្ដាប់ធ្នាប់ ភ្នាក់ងារទេសចរណ៍ កម្មករជួសជុលប្រាសាទ ឬការងារផ្សេងៗទៀត តាមសមត្ថភាពជាក់ស្ដែង។

តាមរយៈការងារទាំងនេះ ប្រជាពលរដ្ឋតែងរកបានចំណូល និងមានជីវភាពរស់នៅសមរម្យផង បានរួមចំណែកក្នុងកិច្ចការអភិរក្សមត៌កដូនតាក្នុងទឹកដីកំណើតរបស់ខ្លួនផង៕









លោកស្រី ភិត សាវឿន អាយុ៣២ឆ្នាំ រស់នៅភូមិប្រដាកក្នុងតំបន់អង្គរ ជាភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទបន្ទាយក្ដីតាំងពីឆ្នាំ២០០៤។

នាងខ្ញុំពិតជាមានមោទនភាពណាស់ ដែលបានបំពេញការងារជាភ្នាក់ងារទេសចរណ៍ ជូនអាជ្ញាធរអប្សរា ក៏ដូចជាបានចូលរួមថែរក្សាឧទ្យានអង្គរ ហើយទទួលបានប្រាក់បៀវត្សជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។



លោក ផល វណ្ណៈ (ជនពិការ) អាយុ២៧ឆ្នាំ នៅភូមិត្រពាំងសេះ ជាភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រសាទភ្នំបាខែង

ខ្ញុំមានអារម្មណ៍សប្បាយក្រៃលែង ដំបូងខ្ញុំមានអារម្មណ៍ថា អាជ្ញាធរអប្សរាប្រហែលជាមិនត្រូវការជនពិការឲ្យបម្រើការជាភ្នាក់ងារទេសចរណ៍ នោះទេ តែខ្ញុំនៅតែសម្រេចចិត្តដាក់ពាក្យ អាជ្ញាធរអប្សរាយល់ឃើញថា ខ្ញុំមានចំណេះដឹង និងសមត្ថភាពសមស្របទៅនឹងលក្ខខណ្ឌការងារ ទើបអនុញ្ញាតឲ្យខ្ញុំបានបំពេញការងារជាភ្នាក់ងារទេសចរណ៍។

ហើយសូមអរគុណចំពោះអាជ្ញាធរអប្សរាដែលបានទទួលខ្ញុំដែលជាជនពិការនេះឲ្យមានឱកាសចូលបម្រើការងារជាភ្នាក់ងារទេសចរណ៍ ៕



# អាជ្ញាធរអប្សរាចូលរួមលើកតម្លៃប្រពៃណី ទំនៀមទម្លាប់ និង សាសនា ក្នុងឧទ្យានអង្គរ

ប្រាកដណាស់ អង្គរ គឺជារមណីយដ្ឋានដែលមានជីវិត ថ្វីត្បិតតែពុំទាន់មានការស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយអំពីកាលបរិច្ឆេទនៃការតាំងទីលំនៅរបស់មនុស្សក៏ដោយ ក៏គេនៅតែអាចដឹងថាទឹកដីខ្វះនៃតំបន់រមណីយដ្ឋានអង្គរ មានមនុស្សនៅតាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ។ ការសន្មត់បែបនេះ ដោយសារឃើញមានសំណល់បុរាណទាំងឡាយនៃដើមប្រវត្តិសាស្ត្រអង្គរ ដែលបង្ហាញថាជំនាន់នោះ សហគមន៍មនុស្សតាំងលំនៅដ្ឋានជុំវិញប្រាសាទផ្សេងៗ មិនខុសពីការតាំងទីរស់នៅសព្វថ្ងៃនេះប៉ុន្មានទេ។ តាមរយៈការប្រាស្រ័យយ៉ាងជិតស្និតរវាងមនុស្ស និងបេតិកភណ្ឌ (ប្រាង្គប្រាសាទ) ធ្វើឱ្យអ្នកស្រុក(ប្រជាពលរដ្ឋដែលតាំងទីរស់នៅក្នុងរមណីយដ្ឋានអង្គរតាំងពីដូនតាមក) ប្រកាន់បានយ៉ាងខ្ជាប់ខ្ជួននូវទំនៀមទម្លាប់ប្រពៃណីដូនតារបស់ខ្លួន។ មួយវិញទៀត មានប្រពៃណីមួយចំនួនដែលជាប្រពៃណីផ្ទាល់នៃតំបន់នេះតែម្តង ឥតឃើញមានជាទំនៀមនៅតំបន់ឬខេត្តណាផ្សេងឡើយ នេះសបញ្ជាក់ឱ្យឃើញនូវមរតកវប្បធម៌និងប្រវត្តិសាស្ត្រដ៏មានតម្លៃនៃរមណីយដ្ឋានអង្គរ។

ដើម្បីការពារថែរក្សា និងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិទាំងរូបី និងអរូបីនៅក្នុងតំបន់សៀមរាបអង្គរ អាជ្ញាធរអប្សរាបានបង្កើត «បទដ្ឋានគ្រប់គ្រងបេតិកភណ្ឌអរូបី» ដោយស្របទៅតាមច្បាប់ស្តីពីកិច្ចការពារវប្បធម៌ អនុសញ្ញាឆ្នាំ១៩៧២ ស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោក ផ្នែកវប្បធម៌និងធម្មជាតិ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងន័យនេះអាជ្ញាធរអប្សរាបានបង្កើតគម្រោង «ការស្រាវជ្រាវបេតិកភណ្ឌអរូបីនៅក្នុងឧទ្យានអង្គរ» កាលពីខែមេសា ឆ្នាំ២០១០ ហើយ បានរៀបចំតាក់តែង «លំនាំបទដ្ឋានស្តីពីការគ្រប់គ្រង ការពារបេតិកភណ្ឌវប្បធម៌អរូបី នៅក្នុងតំបន់អង្គរ និងតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា»។

ដោយសារតែមានហេតុផលគតិយុត្តនិងតម្លៃវប្បធម៌អរូបីនេះបានជានៅឆ្នាំ២០១៣អាជ្ញាធរអប្សរាបានរៀបចំសិក្ខាសាលា ដើម្បីពិគ្រោះពិភាក្សា និងផ្លាស់ប្តូរយោបល់ជាលក្ខណៈទូលំទូលាយ លើសេចក្តីព្រាងស្តីពីលំនាំបទដ្ឋានខាងលើ ដោយមានការចូលរួមពីព្រះសង្ឃ អាជ្ញាធរមូលដ្ឋាន ព្រមទាំងចាស់ព្រឹទ្ធាចារ្យក្នុងមូលដ្ឋាន និងតំណាងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ផងដែរ។

ក្នុងសកម្មភាពជាក់ស្តែងអាជ្ញាធរអប្សរា តាមរយៈក្រុមការងារសហគមន៍បានចូលរួមលើកកម្ពស់វប្បធម៌ប្រពៃណី ទំនៀមទម្លាប់របស់របស់អ្នកស្រុកអង្គរ តាមរយៈការចូលរួមសកម្មភាពជាមួយគាត់ដូចជាពិធីកាន់បិណ្ឌ បុណ្យកឋិនជាដើម និងចូលរួមថវិកាក្នុងពិធីប្រពៃណីផ្សេងៗ ស្រាវជ្រាវចងក្រងជាឯកសារផ្សព្វផ្សាយអំពីទំនៀមទម្លាប់តាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់អាជ្ញាធរអប្សរា និងសហការជាមួយដៃគូផ្សព្វផ្សាយនានា។ល។











## ពិធីបុង្គក្រឡាន

ពិធីដែលគេយកក្រឡាន រួមនឹងផ្លែឈើ ភោគផលជាច្រើនប្រភេទ ទៅបុង្គចោលដើម្បីឲ្យព្រះសង្ឃនិមន្តទៅទស់យកហៅថា ពិធីបុង្គក្រឡាន។ អ្នកអង្គរនិយមធ្វើពិធីនេះនៅក្រោយរដូវច្រូតកាត់ហើយ។ គេតែងធ្វើនៅពេលរសៀលនិងបន្តរហូតដល់យប់ជ្រៅ។ គោលបំណងនៃពិធីគឺអបអរការប្រមូលផលកសិកម្ម និងធ្វើបុណ្យឧទ្ទិសដល់ញាតិកាដែលបានស្លាប់ទៅហើយ។

កម្មវិធីសំខាន់ៗដែលគេធ្វើក្នុងពិធីនេះមានដូចជា គេរៀបចំគ្រឿងរណ្តាប់មាន ក្រឡាន អន្សម ផ្លែឈើ ត្រី សាច់ អំបិល ស្ករស ធូបទៀនយកមកបុង្គចោលនៅកន្លែងណាមួយនៃពិធី ហើយគ្របស្លឹកឈើពីលើរួចអុជធូបទៀន។ បន្ទាប់មកក៏និមន្តព្រះសង្ឃសមាទានសីល ហើយនិមន្តព្រះសង្ឃមួយអង្គធ្វើធុតង្គបីជុំយ៉ាងស្ងប់ស្ងាត់ដើម្បីទាករបស់ទាំងនោះ។ អ្នកចូលរួមអង្គុយសំពះដោយក្តីគោរព និងស្ងៀមស្ងាត់បំផុត។









# ពិធីបួងសួងសុំទឹកភ្លៀងអ្នកស្រុកអង្គរ នៅប្រាសាទនាគព័ន្ធ

នាគព័ន្ធជាប្រាសាទដែលអ្នកស្រុកអង្គរយល់ថា មានភាពសក្តិសិទ្ធិអាចផ្តល់ទឹកភ្លៀងតាមសេចក្តីត្រូវការនៅពេលជួបគ្រោះរាំងស្ងួត។ អ្នកអង្គរតែងប្រារព្ធពិធីសុំទឹកភ្លៀងជាប្រចាំ នៅពេលដែលដល់រដូវធ្វើស្រែហើយនៅមិនទាន់មានភ្លៀងធ្លាក់គ្រប់គ្រាន់។

កម្មវិធីដែលគេធ្វើក្នុងពិធីនេះគឺ ការរៀបចំពិធីប្រុងពលី ប្រកាសបួងសួង និងសែនគ្រឿងសំណែនផ្សេងៗ ព្រះសង្ឃសូត្រធម៌ព្រះបរិត្ត និងធម៌មហាមេឃ ការបញ្ចូលរូប ពេលព្រឹកឡើង គេនិមន្តព្រះសង្ឃឆាន់យាគូ និងរាប់បាត្រព្រះសង្ឃតាមទំនៀមព្រះពុទ្ធសាសនា។ មុននឹងបញ្ចប់កម្មវិធី អាចារ្យនាំអ្នកស្រុកដើរប្រទក្សិណប្រាសាទនាគព័ន្ធ ៣ជុំ ដោយចាក់ទឹកលើក្បាលទ (អ្នកស្រុកហៅថា រន្ធរាហូ) ដែលមានចម្លាក់រូបសំណាកនៅតាមទិសទាំងបួន។ មិនតែប៉ុណ្ណោះ អ្នកស្រុកក្មេងចាស់លេងជះទឹកដាក់គ្នាទៅវិញទៅមក ខ្លះច្រៀង ខ្លះរាំ សប្បាយក្អាកក្អាយ ហាក់ដូចជាកំពុងភ្លៀងធ្លាក់មកមែនទែន។

# ពិធីបុណ្យឆ្លងផ្លូវ នៅលាងដៃ

នៅពេលបានសមិទ្ធផលអ្វីមួយថ្មីៗ អ្នកអង្គរនិយមធ្វើពិធីមួយគឺបុណ្យឆ្លង។ បុណ្យឆ្លង គេធ្វើឡើងដើម្បីអបអរសាទរនឹងសមិទ្ធផលថ្មីនោះផង ដើម្បីសុំសេចក្តីសុខចម្រើនដល់អ្នកប្រើប្រាស់សមិទ្ធផលនោះផង។ ជាក់ស្តែង ក្រោយពីទទួលបានផ្លូវលំក្រាលគ្រួសក្រហមមួយខ្សែ ពីអាជ្ញាធរអប្សរា អ្នកភូមិលាងដៃបាននាំគ្នាប្រារព្ធពិធីឆ្លងផ្លូវយ៉ាងគគ្រឹកគគ្រេង។

ពិធីសំខាន់ៗក្នុងបុណ្យឆ្លងផ្លូវនេះមានដូចជា ពិធីប្រុងពលី ពិធីលើកទង់ បួងសួង និមន្តព្រះសង្ឃចម្រើនព្រះបរិត្តបញ្ចូលរូប និងថ្ងៃចុងក្រោយគឺ ពិធីរាប់បាត្រដារឆ្លង៕









# ពិធីកោរជុក ឬកោរកំប៉ោយ



រានកោសម្រាប់ធ្វើពិធីកោរជុក និងស្រោចទឹក



ក្មេងៗអង្គុយសំពះព្រះសង្ឃសូត្រមន្ត ដោយគងព្រះខ័នលើស្មាខាងស្តាំ



លោកតាអាចារ្យឲ្យក្មេងបៀមថ្នាំក្នុងពិធីធ្វើធ្មេញ

ពិធីនេះស្ទើរតែបាត់បង់អស់ទៅហើយពីប្រទេសកម្ពុជា លើកលែងតែនៅតំបន់ខ្លះ ជាពិសេសតំបន់អង្គរ និងភាគខាងជើងឬពាយព្យនៃប្រទេស។ ពិធីនេះហៅជាផ្លូវការ "កោរជុក" តែសម្តីអ្នកស្រុកខ្លះហៅថា "កោរសក់ ឬកោរកំប៉ោយ" ។ កំប៉ោយឬជុកនោះ ជាសក់មួយដុំ ឬច្រើនដុំ(ច្រើនបំផុតបីកំប៉ោយ) ដែលក្មេងប្រុសស្រីទុកនៅលើក្បាល ចាប់អាយុ៣ឆ្នាំជាដើម រហូតដល់ឡើងកោរ។ រាល់ពេលកាត់សក់សម្អាតជាធម្មតានោះ គឺគេកោរតែប៉ែកដែលនៅជុំវិញកំប៉ោយប៉ុណ្ណោះ ទុកឲ្យកំប៉ោយនោះនៅជាសក់ដុំវែង ឬខ្វីដាច់តែឯង។



កាផ្ទេរមរតករបស់ដូនតាខ្មែរពីជំនាន់មួយទៅជំនាន់មួយ ពួកគាត់មរតករស់ដ៏មានតម្លៃដែលមិនអាចកាត់ថ្លៃបាន។

ពិធីនេះជាការរៀបចំឲ្យសាមីខ្លួនត្រៀមនឹងចូលក្នុងភាពពេញវ័យ។ ហេតុនេះហើយទើបត្រូវធ្វើមុនពេលពេញវ័យជាដាច់ខាត ហើយម្យ៉ាងទៀត ដោយសារនេះជាការត្រៀមលក្ខណៈ ក៏មិនត្រូវធ្វើមុនពេលយូរពេកឡើយ។ ជាធម្មតាគេធ្វើនេះរយៈពេល៣ថ្ងៃ ដោយរាប់ទាំងថ្ងៃឡើងរោង ថ្ងៃពិធី និងថ្ងៃចុងក្រោយឆ្លងពិធីផង។ កិច្ចពិធីដែលត្រូវធ្វើទៀតសោតក៏មានច្រើនណាស់ ដោយរាប់ទាំងពិធីប្រុងពលី ពិធីដេកអង្កររាប រាវអង្កររាប ហៅព្រលឹង ជញ្ជាត់ព្រលឹង ធ្វើធ្មេញ កោរជុកស្រោចទឹកលើក្បាលក្មេង។ល។



អាជ្ញាធរអបអរភ្ជាប់ចិណ្ឌនៅវត្តរលួស



(បុណ្យសង្ឃទាននៅសាលាឆទាននៅ ឃុំដូនកែវ ស្រុក ក្នុងរមណីយដ្ឋានអង្គរ)



ស័ង្កសី៧៥សន្លឹក ដើម្បីជួសជុលដំបូលសាលាឆទាននៅភូមិតាប៉ាង សង្កាត់អំពិល ក្រុងសៀមរាប



អាជ្ញាធរអប្សរាប្រគេនទេយ្យទានដល់ព្រះសង្ឃនៅវត្តភ្នំបូក

# គម្រោងអភិវឌ្ឍន៍សហគមន៍

ក្រៅតែពីការងារអភិរក្សនិងថែរក្សាឱ្យបាននូវតម្លៃជាសកលនៃរមណីយដ្ឋានអង្គរដែលមាន ប្រាសាទ ទេសភាពវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ សាសនា អាជ្ញាធរអប្សរាក៏បានយកចិត្តទុកដាក់ជាខ្លាំងអំពីការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ។ ស្របតាមទស្សនទាននេះ អាជ្ញាធរអប្សរាបានកំណត់នូវអាទិភាពការងារច្បាស់លាស់ សំដៅលើកកម្ពស់ការងារអភិវឌ្ឍន៍សហគមន៍ ដើម្បីកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋតាមរយៈការទទួលចំណូលបានពីវិស័យទេសចរណ៍។

ការកំណត់នូវការងារអាទិភាពបែបនេះ គឺធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុង រមណីយដ្ឋានអង្គរ ទទួលបាននូវផលប្រយោជន៍ដោយផ្ទាល់ពីការរីកលូតលាស់នៃវិស័យទេសចរណ៍។ ដូច្នេះ ចំណូលដែលបានមកពីវិស័យទេសចរណ៍ទាំងនេះត្រូវបានទៅដល់ដៃប្រជាពលរដ្ឋដោយផ្ទាល់ហើយ ប្រជាពលរដ្ឋទាំងនោះក៏ជាអ្នកស្រុកដែលកំពុងតែបានចូលរួមថែរក្សានូវទិដ្ឋភាពដ៏ផូរផង់នៃបេតិកភណ្ឌអង្គរ។





# ការងារអភិវឌ្ឍន៍កសិកម្ម និងសហគមន៍



*សកម្មភាពពិសោធន៍ ពិនិត្យមីក្រូទស្សន៍មើលអតិសុខុមប្រាណមានក្នុង អ៊ីអឹមខ្មែរ (KEM) ដែលមានគុណប្រយោជន៍ដល់ការលូតលាស់របស់សត្វ រុក្ខជាតិ និងប្រើជាថ្នាំបណ្តេញសត្វល្អិតចង្រៃ អាជ្ញាធរអប្សរាចែកជូនបងប្អូនប្រើប្រាស់ក្នុងវិស័យកសិកម្ម*

ឧទ្យានអង្គរគ្របដណ្តប់លើផ្ទៃដី ៤០១ គីឡូម៉ែត្រការ៉េ ដែលមាន ១១២ភូមិ ២១ឃុំ និង៥ស្រុកគឺ ៖ សៀមរាប ពួកអង្គរធំ ប្រាសាទបាគង និងបន្ទាយស្រី ជាតំបន់មានទេសភាពវប្បធម៌ វាលស្រែធំល្វឹងល្វើយ ប្រាង្គប្រាសាទ និងភូមិឋានរបស់អ្នកស្រុក។ ស្ថានភាពភូមិសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចក្នុងតំបន់ អំណោយផលឲ្យយើងចាប់យកវិស័យ **កសិកម្ម សិប្បកម្ម និងទេសចរណ៍** សម្រាប់អភិវឌ្ឍសហគមន៍ ដោយផ្សារភ្ជាប់ជាមួយកិច្ចថែរក្សាការពារ រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ។ តាមរយៈកិច្ចប្រជុំ នៅទីក្រុងប៉ារីស ឆ្នាំ២០០៣ អង្គការយូណេស្កូ តម្រូវឲ្យការអភិវឌ្ឍន៍តំបន់បុរាណវិទ្យាអង្គរត្រូវតែប្រកបដោយនិរន្តរភាព ។

ឧទ្យានអង្គរត្រូវបានចំណាត់ថ្នាក់ជារមណីយដ្ឋានរស់ មានន័យថា បេតិកភណ្ឌ ធម្មជាតិ និងមនុស្ស រស់នៅជាមួយគ្នា ដូច្នេះចក្ខុវិស័យរបស់នាយកដ្ឋានកសិកម្ម និងសហគមន៍គឺ "ការអភិវឌ្ឍប្រកបដោយចីរភាព នៅតំបន់សៀមរាប-អង្គរ ពិសេសការអភិវឌ្ឍសង្គម និងសហគមន៍ក្នុងតំបន់១ និងតំបន់២ លើការងារប្រជាសាស្ត្រ និងការអភិវឌ្ឍកសិកម្មតាមបែបជីវធម្មជាតិ"។ តាមស្ថានភាពភូមិសាស្ត្រតំបន់អង្គរជាវាលទំនាបនៃបឹងទន្លេសាប ការប្រើប្រាស់សារធាតុគីមី នឹងបង្កឲ្យមានផលប៉ះពាល់ខ្លាំង ដល់តំបន់ដែលនៅខាងក្រោម ជាពិសេសគឺធនធានមច្ឆាជាតិនៅក្នុងបឹងទន្លេសាប អាជ្ញាធរអប្សរាបានខិតខំប្រឹងប្រែងរិះរកបច្ចេកទេសកសិកម្មតាមបែបធម្មជាតិទៅផ្សព្វផ្សាយប្រជាពលរដ្ឋរស់នៅក្នុងឧទ្យានអង្គរ យើងធ្វើការពិសោធ ឬដាំបង្ហាញនៅក្នុងស្ថានីយ៍កសិកម្មជាមុនសិនមុននឹងយកទៅផ្សព្វផ្សាយជូនបងប្អូនអនុវត្ត។ ដើម្បីដោះស្រាយនូវតម្រូវការផ្គត់ផ្គង់ចំណីអាហារ ផ្គត់ផ្គង់ទីផ្សារទេសចរណ៍ បញ្ហាដីមានជាតិអាស៊ីត ដីប្រភេទខ្សាច់ ដីខ្វះជីជាតិ



អ៊ីអឹមខ្មែរ (KEM) ប្រើប្រាស់កាត់បន្ថយអត្រាស្លាប់លើការចិញ្ចឹមមាន់




ផលិតពូជស្រូវសម្រាប់ចែកជូនប្រជាកសិករក្នុងតំបន់អង្គរ



ដីកំប៉ុស្តដែលអាផ្សាធរអប្សរាផលិតសម្រាប់ចែកជូនប្រជាកសិករអង្គរ



ក្រុមចង់ក្រង និងសម្របសម្រួលក្រុមសន្សំប្រាក់តាមភូមិ

ការប្រើប្រាស់វិធីសាស្ត្រដាំដុះតាមធម្មជាតិទទួលបានទិន្នផលទាប។ ការប្រើប្រាស់ដីកំប៉ុស្តមួយមុខគឺមិនគ្រប់គ្រាន់ទេ ការប្រើប្រាស់ដីអាចប្រចៀវដែលជាដីលេខមួយនៅមានតម្លៃថ្លៃ។ នាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍ របស់អាជ្ញាធរអប្សរា បានស្រាវជ្រាវនូវប្រភេទ អ៊ីអឹមខ្មែរ(Khmer Efficiency Microorganism) ជាប្រភេទថ្នាំប៉ូវប្រើសម្រាប់មនុស្ស សត្វ និងរុក្ខជាតិ មកលាយបន្ថែមលើដីធម្មជាតិ និងចំណីសត្វ(ដាក់ក្នុងទឹកឲ្យមាន់ផឹក ស្រះចិញ្ចឹមត្រី...) ជួយឲ្យដីកំប៉ុស្តមានគុណភាពទ្វេដង សត្វចិញ្ចឹមមានសុខភាពល្អ (ធន់នឹងជម្ងឺ) ជាពិសេសសត្វមាន់ ថែមទាំងជំរុញឲ្យកើនឡើងនូវអតិសុខុមប្រាណនៅក្នុងដីជំរុញដល់ការកែប្រែគុណភាពដីបានល្អប្រសើរ ហើយក៏ជាវត្ថុធាតុដើមក្នុងការផលិតថ្នាំបណ្តេញសត្វល្អិតចង្រៃយ៉ាងមានប្រសិទ្ធភាព ជៀសវាងបានពីការប្រើប្រាស់ថ្នាំពុលគីមីដែលមានគ្រោះថ្នាក់ដល់សុខភាព និងបរិស្ថាន។

កត្តាគន្លឹះទាំងអម្បាលមាណ ដែលនាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍ បានរួមចំណែកក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងតំបន់អង្គរមិនតែប៉ុណ្ណោះយើងបានប្រើប្រាស់ក្នុងការងារអភិវឌ្ឍន៍កសិកម្មតាមបែបធម្មជាតិក្នុងគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ឈានទៅដល់ការកាត់បន្ថយភាពក្រីក្ររបស់អ្នកស្រុកអង្គរ ។

ក្រៅពីការងារខាងលើ តាំងពីឆ្នាំ២០០៨មក នាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍ បានចងក្រង និងសម្របសម្រួលជា ក្រុមសន្សំប្រាក់តាមសហគមន៍ ចំនួន៣០ភូមិ មាន៤០ក្រុម យើងប្រើប្រាស់ក្រុមសន្សំប្រាក់ក្នុងគោលដៅសំខាន់ៗដើម្បីបង្កើតទុនសម្រាប់មុខរបររបស់បងប្អូនប្រជាពលរដ្ឋជាពិសេសលើកសិកម្មធម្មជាតិ ចែករំលែកព័ត៌មានសម្ភារៈចង្អុលទិស ផ្លាស់ប្តូរផ្ទត់គំនិត និងអប់រំអំពី ទិសដៅនៃការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងរមណីយដ្ឋាន។

# គម្រោងអភិវឌ្ឍន៍
# ភូមិធម្មជាតិរុនតាឯក



ភូមិធម្មជាតិរុនតាឯកបានបង្កើតឡើងក្នុងគោលបំណង ទទួលយកគ្រួសារថ្មីរបស់កូនចៅអ្នកស្រុកអង្គរដែលស្ម័គ្រចិត្តទៅរស់នៅទីនោះបន្ទាប់ពីបានបំបែកផ្ទះពីឪពុកម្ដាយក្រោយពេលរៀបការរួចៗ ភូមិធម្មជាតិរុនតា ឯ កនេះ ត្រូវបានអាជ្ញាធរអប្សរាអភិវឌ្ឍន៍ទាំងស្រុងដែលមានទាំងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្ទះ សាលារៀន សាទ្បុំ មជ្ឈមណ្ឌលបណ្ដុះបណ្ដាល ប៉ុស្ដិ៍សុខភាព និងផ្សារក្នុងភូមិជាដើមៗ

ផ្ទៃដីសរុបនៃភូមិធម្មជាតិនេះមានចំនួន ១.០១២ហិកតា ក្នុងនោះប្រឡាយ ផ្លូវជុំវិញ និងផ្លូវខាងក្នុង ប្រមាណ១៦០ហិកតា ចំណែកដីសម្រាប់សាងសង់លំនៅដ្ឋាន និងកសិកម្មមាន ប្រមាណ ៨៥២ ហិកតា ដែលអាចទទួលប្រជាពលរដ្ឋ ៨៥០គ្រួសាររស់នៅទីនេះៗ

បច្ចុប្បន្នភូមិធម្មជាតិរុនតាឯកទទួលបានប្រជាពលរដ្ឋមករស់នៅ ១០៣គ្រួសារហើយស្ថិតក្នុងចំណោម ប្រជាពលរដ្ឋដែលបានដាក់ពាក្យ១២៦គ្រួសារកន្លងមក ៗ

អាជ្ញាធរអប្សរាមានគម្រោងទទួល៨០ គ្រួសារបន្ថែមក្នុងមួយឆ្នាំដោយគិតចាប់ពីឆ្នាំ ២០១៦ រហូតដល់ឆ្នាំ២០២០ៗ

ដើម្បីលើកស្ទួយជីវភាពរបស់បងប្អូន អាជ្ញាធរអប្សរាបានផ្ដល់ការថែរ ថែមទាំង បណ្ដុះបណ្ដាលជំនាញ កសិកម្ម និង សិប្បកម្មដល់ពួកគាត់ បូកបញ្ចូលទាំងការបង្កើតមុខរបរជូនពួកគាត់ទៀតផងៗ





ផ្ទាំងសូឡាសាកអាគុយដើម្បីបរិស្ថាន



សកម្មភាពភ្ញៀវទេសចរស្ទូងស្រូវ



បន្លែគ្មានជាតិគីមីនៅភូមិធម្មជាតិរុនតាឯក



ដីចម្ការរបស់ប្រជាជន



ពិធីបុណ្យប្រពៃណីក្នុងភូមិធម្មជាតិរុនតាឯក



កម្មវិធីចែកគ្រាប់ពូជ និងសៀវភៅកសិកម្ម



សកម្មភាពដាំកូនឈើរបស់ទេសចររុនតាឯក



កូនមាន់ពូជដែលនឹងចែកជូនកសិករ រុនតាឯក









ដើម្បីជួយសម្រួលដល់ការធ្វើដំណើរដឹកកសិផលបំពេញតាមតម្រូវការនៃជីវភាពរបស់ប្រជាពលរដ្ឋ អាជ្ញាធរអប្សរាបានរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសំខាន់ៗដូចជាផ្លូវថ្នល់សាលារៀនប្រព័ន្ធទឹកស្អាតប្រព័ន្ធរំដោះទឹកចេញពីភូមិ ការរៀបចំអគ្គិសនីប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ និងបានសាងសង់សាទ្បុំជាមណ្ឌលសាសនាសម្រាប់ជាទីសក្ការៈគោរពបូជា។ សង់ផ្ទះគំរូ និងចម្ការគំរូដែលមានផ្ទៃដីសរុប៩ហិកតា សម្រាប់បង្ហាញពីរបៀបធ្វើកសិកម្ម ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ជូនដល់ប្រជាពលរដ្ឋដែលរស់នៅទីនោះ។ ចម្ការគំរូ មានការដាំបង្ហាញស្រូវ ដំណាំហូបផ្លែ និងដំណាំកសិកម្មផ្សេងៗដែលសមស្របទៅនឹងគុណភាពដីនៅភូមិសាស្ត្រនេះ។

ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិធម្មជាតិរុនតាឯក បានទទួលវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបន្ថែមជាច្រើន ជាពិសេសផ្នែកកសិកម្ម តាមរយៈអ្នកជំនាញរបស់អាជ្ញាធរអប្សរា និង អ្នកជំនាញឯកជនដែលជាដៃគូសហការរបស់អាជ្ញាធរអប្សរា។ ដោយគោលដៅកសិកម្មមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋក្នុងភូមិធម្មជាតិរុនតាឯកនេះ អាជ្ញាធរអប្សរាក៏បានដឹកនាំក្រុមសមាជិកកសិករគំរូទៅធ្វើទស្សនកិច្ចសិក្សានៅតំបន់ផ្សេងៗ ធ្វើយ៉ាងណាទទួលបាននូវបទពិសោធន៍របៀបរបបកសិកម្មមកអនុវត្តឲ្យបានជោគជ័យ ដើម្បីអាចទាញយកចំណាប់អារម្មណ៍របស់ទេសចរមកទស្សនាកម្សាន្តនិងទិញយកផលិតផលកសិកម្មនៅនឹងកន្លែង។










នៅភូមិធម្មជាតិរុនតាឯកមានប្រព័ន្ធសន្តិសុខ២៤ម៉ោង បូករួមនិងទេសភាពធម្មជាតិ ដូចជាបឹងជាលាធំ និងព្រៃធម្មជាតិជាដើម ដែលអាចទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិមកទស្សនាកម្សាន្តបាន អាជ្ញាធរអប្សរាបានរៀបចំឲ្យមានគម្រោងភ្ញៀវទេសចរជាតិ និងអន្តរជាតិ ប្រមាណជាង២.៤៦៧នាក់ហើយ មកទស្សនា និងស្នាក់នៅភូមិធម្មជាតិរុនតាឯក។ ប្រជាពលរដ្ឋក្នុងភូមិបានទាញចំណូលពីវិស័យទេសចរណ៍នេះតាមរយៈ ការជួលផ្ទះ ស្ទូងស្រូវ អាហារសម្រន់បែបប្រពៃណីមានដូចជា ការដុតក្រឡាន ដាំកូនឈើ អាហារថ្ងៃត្រង់ អាហារពេលល្ងាច និងការលក់ផលិតផលកសិកម្ម និងសិប្បកម្មដោយផ្ទាល់ជូនដល់ភ្ញៀវទេសចរ។















# សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ ទេសចរណ៍បាពាយណ៍ពជដាក

ដោយមើលឃើញពីសក្តានុពលទេសចរណ៍ ក្នុងតំបន់បាពាយណ៍ពជដាក អាជ្ញាធរអប្សរាបានរៀបចំឱ្យមាន សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ទេសចរណ៍បាពាយណ៍ពជដាកនេះឡើងនៅឆ្នាំ២០១៣ ។

ក្នុងដំណើរកំសាន្តរបស់ភ្ញៀវទេសចរ ពួកគេអាចធ្វើដំណើរកំសាន្តជាដំណាក់ៗ ក្នុងនោះភ្ញៀវទេសចរត្រូវដើរដោយថ្មើរជើង និង ជិះទូកកំសាន្ត។ ភ្ញៀវទេសចរអាចទស្សនាសត្វស្លាបព្រៃលិចទឹកព្រមទាំងជីវចំរុះក្នុងបាពាយណ៍ពជដាក។ ក្រៅពីទស្សនាទេសភាពធម្មជាតិព្រៃ និងព្រៃលិចទឹក ភ្ញៀវអាចបន្តទស្សនានូវទេសភាពវប្បធម៌ ការរស់នៅរបស់ប្រជាជន សិប្បកម្ម កសិកម្មធម្មជាតិនានា ក្នុងទិសដៅការពារថែរក្សាទេសភាពធម្មជាតិ និង បេតិកភណ្ឌវប្បធម៌ក្នុងមូលដ្ឋានរបស់សហគមន៍។

ចំណូលដែលទទួលបានពីការទស្សនារបស់ភ្ញៀវទេសចរ ត្រូវបានក្លាយជាប្រយោជន៍ដោយផ្ទាល់ជូនដល់សហគមន៍មូលដ្ឋានដើម្បីអភិវឌ្ឍន៍ក្នុងភូមិក្វង់ និងភូមិលាងដៃ ដែលស្ថិតនៅក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ។ លើសពីនេះទៅទៀត ចំណូលទាំងនោះក៏ត្រូវបានយកទៅប្រើប្រាស់សម្រាប់បណ្តុះបណ្តាលជំនាញភាសាបរទេស គណនេយ្យ មគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងផ្នែកទីផ្សារដើម្បីប្រជាពលរដ្ឋក្នុងសហគមន៍អាចប្រាស្រ័យទំនាក់ទំនងជាមួយភ្ញៀវទេសចរមកពីទូទាំងពិភពលោក៕









# សហគមន៍ទេសចរណ៍ ជិះទូកបន្ទាយស្រី



សហគមន៍ទេសចរណ៍ជិះទូកបន្ទាយស្រី ជាផ្នែកមួយនៃគម្រោង PARVISបន្ទាយស្រី ដើម្បីឲ្យប្រជាពលរដ្ឋភូមិបន្ទាយស្រី និងភូមិទូលក្រឡាញ់ ទទួលបានផលពីវិស័យទេសចរណ៍ប្រាសាទបន្ទាយស្រី ។

សហគមន៍ទេសចរនេះផ្តល់ជូនភ្ញៀវទេសចរ នូវការស្ទូចត្រី និង ជិះទូកកំសាន្តលើត្រពាំងស្រែព្រៃ នៅផ្នែកខាងជើងប្រាសាទបន្ទាយស្រី។ ភ្ញៀវទេសចរអង្គុយលំហែ ស្រស់ស្រូបអាហារ មានទឹកដូង និងភេសជ្ជៈផ្សេងៗ នៅលើរានហាលដែលមានស្រាប់នៅទីនោះជាពិសេសគឺ ចម្អិនត្រីដែលភ្ញៀវស្ទូចបាន។

ចំណូលទាំងឡាយដែលបានមកពីសកម្មភាពដូចរៀបរាប់ខាងលើ ត្រូវបានបែងចែកដូចជា៖ ២៣% សម្រាប់សមាជិកដែលចូលរួម ២៨% សម្រាប់រដ្ឋបាលនិងផ្សព្វផ្សាយទំនាក់ទំនងទូទៅ ១៤% សម្រាប់ថែទាំតូប និងវង់ទស្សនា និង១៥%ទៀត សម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់ភូមិទាំងពីរ ដូចជា ថែទាំសាលារៀន និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិជាដើម៕





# គម្រោងអភិវឌ្ឍន៍សហគមន៍ សហការជាមួយដៃគូរអន្តរជាតិ

តំបន់អង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោក និងជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលអាជ្ញាធរអប្សរាមានភារកិច្ចរៀបចំ គ្រប់គ្រង ថែរក្សា និងអភិវឌ្ឍប្រកបដោយចីរភាព។ បន្ទាប់ពីតំបន់អង្គរត្រូវបានអង្គការUNESCO លុបឈ្មោះចេញពីបញ្ជីបេតិកភណ្ឌប្រឈមនឹងគ្រោះថ្នាក់នៅឆ្នាំ២០០៤រួចមក។ អាជ្ញាធរអប្សរាបានយកចិត្តទុកដាក់រៀបចំអភិវឌ្ឍដោយពេញលេញអំពីជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ។

ចាប់តាំងពីឆ្នាំ២០០៩ រហូតមកដល់បច្ចុប្បន្ន អាជ្ញាធរអប្សរាបានសហការជាមួយប្រទេសញ៉ូវហ្សឺឡែនក្នុងគោលបំណងដើម្បី "បង្កើនជីវភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អង្គរ និងថែរក្សាការពារបេតិកភណ្ឌ និងធនធានធម្មជាតិប្រកបដោយចីរភាព ដោយមានការចូលរួមពីប្រជាពលរដ្ឋ" ។ តាមរយៈការបង្កើតគម្រោងសហការនេះអាជ្ញាធរអប្សរាបានបង្កើតសកម្មភាពមួយចំនួន ដើម្បីបង្កើនបន្ថែមលើជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរួមមាន៖

-សហគមន៍សេដ្ឋកិច្ចគ្រួសារ និងបរិស្ថាន
-សហគមន៍ទេសចរណ៍
-សហគមន៍អប់រំបេតិកភណ្ឌ
-សហគមន៍ទឹកស្អាត និងសុខាភិបាល
-សហគមន៍សន្សំប្រាក់ និងជួយខ្លួនឯង
-សហគមន៍សិប្បកម្ម

សកម្មភាពទាំងអស់នេះ អាជ្ញាធរអប្សរាបានអនុវត្តលើភូមិចំនួន១៦ភូមិ រួចមកហើយ និងគ្រោងអនុវត្តឱ្យបាន៥០ភូមិ ក្នុងទិសដៅរបស់គម្រោងដែលបញ្ចប់នៅឆ្នាំ២០១៩ អាជ្ញាធរអប្សរានឹងអនុវត្តបន្តដោយខ្លួនឯងឱ្យបានគ្រប់ទាំង១១២ភូមិ ក្នុងតំបន់អង្គរ។







## សហគមន៍ អប់រំបេតិកភណ្ឌ






បង្កើតឡើងដើម្បីអប់រំផ្សព្វផ្សាយអំពីបេតិកភណ្ឌដល់សហគមន៍ សិស្សសាលា និងព្រះសង្ឃ។ គម្រោងនេះបានអប់រំសហគមន៍ និងសិស្សសាលាដោយបង្កើតជាវគ្គសិក្សាមួយវគ្គៗ គម្រោងក៏បានសហការជាមួយអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ បង្កើតសិក្ខាសាលាបណ្តុះបណ្តាលអំពីបេតិកភណ្ឌដល់ព្រះសង្ឃ អាចារ្យ គណៈកម្មការ ដើម្បីបានមូលដ្ឋានធ្វើការផ្សព្វផ្សាយបន្តទៅសហគមន៍ផ្សេងៗ៕

# សហគមន៍ សិប្បកម្ម













ការបង្កើតក្រុមនេះគឺដើម្បីប្រមូលក្រុមសិប្បករក្នុងភូមិដែលមានស្រាប់ឲ្យមកធ្វើរួមគ្នា ដាក់លក់រួមគ្នា បង្កើនសក្តានុពលលក់សិប្បកម្មឲ្យបានច្រើន ហើយដើម្បីឲ្យការងារនេះបានជោគជ័យ គម្រោងបានផ្តល់ជូននូវសម្ភារៈមួយចំនួនសម្រាប់ជំនួយដល់ការងារសិប្បកម្ម និងបើកវគ្គបណ្តុះបណ្តាលជូនពួកគាត់ ឲ្យធ្វើ








ចម្លាក់សិប្បកម្មត្រឹមត្រូវតាមក្បួនខ្នាតរបស់ខ្មែរ បង្កើតរោងចម្លាក់សម្រាប់ធ្វើ និងលក់រួមគ្នានៅក្នុងសហគមន៍ និងតំបន់ទេសចរណ៍ ដូចជារោងលក់សិប្បកម្មក្បែរប្រាសាទតាព្រហ្មជាដើម។









# សហគមន៍កុដិសួរ

សហគមន៍រទេះគោដឹកភ្ញៀវទេសចរ មានទីតាំងនៅភូមិរហាលនិង ស្រះស្រង់ខាងជើង សង្កាត់នគរធំ ក្រុងសៀមរាប បានបង្កើតនៅឆ្នាំ២០០៩ ក្រោមការឧបត្ថម្ភគាំទ្រពីអាជ្ញាធរអប្សរា និងប្រទេសញ៉ូវហ្សឺឡែន។ ដើម្បី លើកតម្លៃបេតិកភណ្ឌវប្បធម៌រូបីអរូបី និងបង្កើនប្រាក់ចំណូលដល់សហ-គមន៍ព្រមទាំងប្រជាពលរដ្ឋបន្ថែមលើប្រាក់ចំណូលដែលបានពីរបរកសិកម្ម សិប្បកម្ម យើងបានសិក្សាលើភូមិដែលមានសក្តានុពលក្នុងវិស័យទេសចរ-ណ៍ សំដៅលើការលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ តាមរយៈដំណើរទស្សនាចរតាមរទេះគោ។

ដំណើរកម្សាន្តតាមរទេះគោជាការកម្សាន្តមួយប្លែក ថែមទាំងបាន បង្ហាញពីទិដ្ឋភាពផ្សេងៗនៃជីវភាពរស់នៅរបស់សហគមន៍ ភ្ញៀវអាចជាវ ផលិតផលសិប្បកម្មពីសហគមន៍ក្នុងភូមិដែលជាសមាជិកសហគមន៍កុដិសួរ ៤ភូមិ ភូមិក្រវ៉ាន់ ស្រះស្រង់ខាងជើង ស្រះស្រង់ខាងត្បូង និងភូមិរហាល។ បើ គិតមកដល់សព្វថ្ងៃ យើងមានរទេះគោ ចំនួន១៥គ្រឿងហើយ។

ប្រាក់ចំណូលមួយផ្នែកសម្រាប់ម្ចាស់រទេះគោ មួយផ្នែកទៀតសហ-គមន៍ប្រើប្រាស់ក្នុងការអភិវឌ្ឍក្នុងភូមិ ដូចជាផ្លូវ សាលាឆទាន និងផ្នែក មនុស្សធម៌ជាដើម។







# ស្ថានីយ៍សាកអាគុយដោយថាមពល ពន្លឺព្រះអាទិត្យ(សូឡា)

គម្រោងស្ថានីយ៍សាកអាគុយដោយថាមពលពន្លឺព្រះអាទិត្យ(សូឡា)បង្កើតឡើងដើម្បីរួមចំណែកដំណោះស្រាយការផ្លាស់ប្តូរកម្តៅផែនដី ផលប៉ះពាល់ដល់បរិស្ថាន និងសោភណភាពក្នុងតំបន់រមណីយដ្ឋានអង្គរ ដោយចំណាយថវិកាតិចក្នុងការសាកអាគុយរបស់ប្រជាពលរដ្ឋក្នុងសហគមន៍អង្គរ ។

គណៈកម្មការប្រើប្រាស់អគ្គិសនីដោយថាមពលព្រះអាទិត្យមួយមានសមាជិក៧រូបអមជាមួយអ្នកកាន់ម៉ាស៊ីនម្នាក់។ ការសាកអាគុយដោយពន្លឺព្រះអាទិត្យគឺថោកជាងការបញ្ចូលអាគុយដោយម៉ាស៊ីនភ្លើង ដូច្នេះហើយចាប់តាំងពីឆ្នាំ២០១២ អាជ្ញាធរអប្សរាសម្រេចបង្កើតស្ថានីយ៍សាកអាគុយចំនួន០៣កន្លែងគឺះ

១.ស្ថានីយ៍សាកអាគុយសហគមន៍ភូមិលាងដៃ ឃុំលាងដៃ ដែលមានផ្ទាំងសូឡាចំនួន១២ផ្ទាំង អាចទទួលសាកអាគុយបាន៣៤អាគុយក្នុង១ថ្ងៃ។ គិតពី២០១៣ ដល់២០១៦ សាកអាគុយបាន ១០.៩១៩ អាគុយ ចំណូលសរុប ១១.៧១៧.៥០០រៀល ដោយបែងចែកចូលហិបសន្សំសហគមន៍ចំនួន ១.៧៥៧.៦០០រៀល ប្រាក់ជួសជុលចំនួន ១.៧៥៧.៦០០រៀល គណៈកម្មការគ្រប់គ្រងចំនួន២.៣៤៣.៥០០រៀល និងម្ចាស់ផ្ទះចំនួន ៥.៨៥៨.៧០០រៀល។

២.ស្ថានីយ៍សាកអាគុយសហគមន៍ភូមិទួលក្រឡាញ់ ឃុំខ្នារសណ្តាយ ដែលមានផ្ទាំងសូឡាចំនួន១៦ផ្ទាំង អាចទទួលសាកអាគុយបាន៤០អាគុយក្នុង១ថ្ងៃ។ គិតពីចុងឆ្នាំ២០១៣ ដល់២០១៦ សាកអាគុយបាន ៩.៩០៦ អាគុយ ចំណូលសរុប ១៣.១១៤.២០០រៀល ដោយហិបសន្សំសហគមន៍ ១.៩៦៧.១០០រៀល ប្រាក់ជួសជុល១.៩៦៧.១០០រៀល គណៈកម្មការ ២.៦២២.៨០០រៀល និងម្ចាស់ផ្ទះ ៦.៥៥៧.១០០រៀល។

៣.ស្ថានីយ៍សាកអាគុយសហគមន៍ភូមិល្បើក ឃុំដូនកែវ ដែលមានផ្ទាំងសូឡាចំនួន១២ផ្ទាំង អាចទទួលសាកអាគុយបាន៤០អាគុយក្នុង១ថ្ងៃ។គិតពីខែមិថុនា ២០១៥ ដល់២០១៦ សាកអាគុយបាន ២.១៧៥ អាគុយ ចំណូលសរុប ១.៨០៨.២០០រៀល ដោយហិបសន្សំសហគមន៍ ២៧០.៧០០រៀល ប្រាក់ជួសជុល ២៧០.៧០០រៀល គណៈកម្មការ ៣៦០.៩០០រៀល និងម្ចាស់ផ្ទះ ៩០២.៤០០រៀល ។

ស្ថានីយ៍សាកអាគុយសហគមន៍ដោយថាមពលពន្លឺព្រះអាទិត្យ បានយកថវិកាមួយផ្នែកទិញអាគុយដើម្បីចែក ជូនដល់សមាជិកសហគមន៍ដែលគ្មានអាគុយប្រើប្រាស់ ចំនួន១៤គ្រួសារដែលជាគ្រួសារមានលទ្ធភាពតិចតួច ឬគ្មានលទ្ធភាព ក្នុងគោលបំណងសម្រាលជីវភាពរបស់ពួកគាត់ដោយមិនចាំបាច់ចំណាយប្រាក់កាសទាំងស្រុងទៅទិញអាគុយនៅទីផ្សារ។













## ក្រុមជួយខ្លួនឯង (សមាគមន៍សន្សំប្រាក់)

អាផ្វាធរអេបូរ៉ាជាអ្នកបង្កើត និងគាំទ្រក្រុម ជួយខ្លួនឯងក្នុងគោលបំណងអភិវឌ្ឍន៍សហគមន៍តាមរយៈការបង្កើនដើមទុន និងការបង្កើតមុខរបរជូនបងប្អូនក្នុងភូមិ ដោយមិនចាំបាច់ទៅខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការបង់ការប្រាក់សងវិញក្នុងកម្រិតខ្ពស់ ។

ក្រុមជួយខ្លួនឯង បានបង្កើតឱ្យមានក្រុមប្រឹក្សាដែលជាអ្នកសម្រេចឱ្យប្រើប្រាស់ប្រាក់ដែលសន្សំបាន និងផ្តល់ជាកម្ចីជូនដល់សមាជិកក្រុម។







# គោលនយោបាយបរិស្ថានរបស់អាជ្ញាធរអប្សរា

## ទស្សនៈបរិស្ថាន

តំបន់អង្គរ-សៀមរាប គឺជាទីតាំងនៃក្រុមប្រាសាទសិលា-និមិត្តរូបនៃប្រទេសជាតិយើង និងជាបេតិកភណ្ឌវប្បធម៌ពិភពលោក ហើយក៏ជាតំបន់ដែលរក្សានូវទំនៀមទម្លាប់ផ្ទាល់របស់អ្នកស្រុក ព្រមទាំងជាតំបន់ដែលគ្របដណ្តប់ដោយព្រៃព្រឹក្សា ស្ទឹង បឹងបួ សម្បត្តិធម្មជាតិដ៏ប្រពៃ ។

យើងខ្ញុំ "អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ" ហៅថា "អាជ្ញាធរអប្សរា" ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ទទួលបន្ទុកគ្រប់គ្រងតំបន់អង្គរ ប្តេជ្ញាចិត្ត ជុំរុញការស្ថាបនាសង្គមមួយ ឈរលើមូលដ្ឋានអភិវឌ្ឍន៍ស៊ីសង្វាក់គ្នារវាង "ធម្មជាតិ ប្រាសាទ និងអ្នកស្រុក" ពោលគឺរវាង "បរិស្ថាន វប្បធម៌ និងសហគមន៍" ដើម្បីធានានូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពសំរាប់ជំនាន់ក្រោយ តាមរយៈសកម្មភាពជួសជុលថែរក្សាប្រាសាទ និងសកម្មភាពអភិវឌ្ឍន៍តំបន់ ដោយសហការជិតស្និទ្ធជាមួយ ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរពាក់ព័ន្ធនានា និងជាមួយប្រជាជនក្នុងតំបន់ទាំងមូល ។

## គោលនយោបាយបរិស្ថាន

១.ជំរុញវិធានការថែរក្សាបរិស្ថានដោយផ្អែកទៅលើទស្សនៈខាងលើ

យើងខ្ញុំនឹងខំខ្នះខ្នែងបង្ការផលប៉ះពាល់ទៅលើបរិស្ថាន តាមរយៈការអនុវត្តយ៉ាងសកម្មនូវវិធានការថែរក្សាបរិស្ថានតំបន់ឲ្យស្របទៅតាមកំណើនភ្ញៀវទេសចរ និងការរីកចំរើនក្នុងវិស័យទេសចរណ៍ ។

២.ចូលរួមធ្វើសកម្មភាពថែរក្សាបរិស្ថានទាំងអស់គ្នាផ្តោតទៅលើ

-ការរៀបចំឧទ្យានអង្គរឲ្យបានស្អាតល្អ និងបង្កើនប្រព័ន្ធគ្រប់គ្រងសំរាមមួយដើម្បីកាត់បន្ថយសំរាម

-ការសម្អាត និងថែរក្សាទឹកស្ទឹង បឹងបួ បារាយណ៍ កសិណជាដើម នៅក្នុងតំបន់ឲ្យបានប្រសើរឡើងវិញ

-ការថែរក្សាការពារធាតុអាកាសឲ្យបានល្អជាប្រចាំ

-ការថែរក្សាការពារព្រៃឈើ -សម្បត្តិធម្មជាតិដ៏មានតម្លៃនៅក្នុងតំបន់ឲ្យបានគង់វង្ស

៣.ធ្វើការអប់រំផ្សាយអំពីបរិស្ថានចំពោះប្រជាជនក្នុងតំបន់

យើងខ្ញុំនឹងធ្វើការអប់រំផ្សព្វផ្សាយអំពីបរិស្ថានចំពោះប្រជាជនក្នុងតំបន់ ក៏ដូចជាចំពោះបុគ្គលិករបស់ខ្លួនដែរដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងនូវសារៈសំខាន់នៃការថែរក្សាបរិស្ថានក្នុងតំបន់ ។

៤.គោរពច្បាប់បញ្ញត្តិ និងតម្រូវការដទៃទៀតផ្នែកបរិស្ថាន

យើងខ្ញុំនឹងគោរពច្បាប់បញ្ញត្តិ ព្រមទាំងការសន្យាទាំងឡាយរបស់ខ្លួនដែលពាក់ព័ន្ធនឹងបរិស្ថាន ហើយនិងជួយណែនាំប្រជាជនក្នុងតំបន់ឲ្យគោរពច្បាប់បញ្ញត្តិ និងវិធានទាំងនេះ ។

៥.ជុំរុញឲ្យមានការកែលម្អឲ្យប្រសើរឡើងជាប្រចាំ

យើងខ្ញុំនឹងស្វែងយល់នូវផលប៉ះពាល់ទៅលើបរិស្ថានដែលកើតចេញពីសកម្មភាព និងចេញពីវិធានការការងាររបស់ខ្លួន រួចហើយយើងខ្ញុំនឹងរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានមួយ ដោយកំណត់យ៉ាងជាក់លាក់នូវ គោលបំណង គោលដៅ និងផែនការការងារបរិស្ថាន ដោយពិនិត្យឡើងវិញជាប្រចាំដើម្បីធ្វើឲ្យមានភាពប្រសើរឡើងជានិរន្តរ៍ ។

៦.គោលនយោបាយបរិស្ថាននេះនឹងត្រូវផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបទៅគ្រប់បុគ្គលិកអាជ្ញាធរអប្សរាទាំងអស់ និងផ្សព្វផ្សាយជាសាធារណៈ ។

សៀមរាប.ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥

**អគ្គនាយកអាជ្ញាធរអប្សរា**

**ស៊ុំ ម៉ាប់**





















អាជ្ញាធរអប្សរាសហការជាមួយ ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តមភ្នំគូលែ
ប្រារព្ធពិធីដាំកូនឈើ៥០០០ដើម នៅបរិវេណប្រាសាទអ្នកតា លើខ្នងភ្នំ











*ាបន និងអង្គការមូលនិធិសម្រាប់ការស្រាវជ្រាវបុរាណវិទ្យានិងអភិវឌ្ឍន៍
ភ្នំគូលែន ស្ថិតក្នុងភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប។*












អាជ្ញាធរអប្សរាប្រារព្ធពិធីដាំកូនឈើចំនួន៥០០០ដើមបន្ថែម សរុបបាន១២.០០០ដើមហើយ
ដែលបានដាំនៅតាមបណ្តោយផ្លូវមិត្តភាពកម្ពុជា-កូរ៉េ









អាជ្ញាធរអប្សរាប្រគេនកូនឈើបេង គគីរ ត្រញ៉ូង និងឈើទាលសរុប ១.៥០០ដើម ដល់ព្រះសង្ឃ
និងពុទ្ធបរិស័ទ ដាំនៅព្រៃចង្ក្រមនៃវត្តដីក្រែងស្ថិតក្នុងភូមិព្រីង ឃុំដីក្រែង ខេត្តសៀមរាប

# ទាំងអស់គ្នាដើម្បីអង្គរ



ឯកឧត្តម បណ្ឌិត ស៊ុំ ម៉ាប់
អគ្គនាយកអាជ្ញាធរអប្សរា

សូមគោរពជនរួមជាតិជាទីស្នេហា ពាក្យស្លោកមួយបានលើកឡើងថា "អភិរក្សដើម្បីអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ដើម្បីពង្រឹងការងារអភិរក្ស" អាជ្ញាធរអប្សរាបង្កើតឡើងក្នុង ឆ្នាំ១៩៩៥ដើម្បីបំពេញបេសកកម្ម តួនាទី និងភារកិច្ចពាក់ព័ន្ធនឹងខ្លឹមសារនៃពាក្យស្លោកនេះ ពោលក្នុងគោលដៅជាអាទិភាពពីរ គឺអភិរក្ស និងអភិវឌ្ឍន៍។ ការងារអភិរក្សសំដៅលើការការពារ ថែរក្សា ទល់ទ្រ ជួសជុល គ្រប់គ្រង និងលើកតម្លៃបុរាណវិទ្យា វប្បធម៌ បរិស្ថាន ទេសភាព និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានអង្គរ ព្រមទាំងរមណីយដ្ឋានផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា។ ទន្ទឹមនឹងការងារអភិរក្ស ការងារអភិវឌ្ឍន៍គឺជាការចាំបាច់។ ការងារអភិវឌ្ឍន៍សំដៅលើការរៀបចំសកម្មភាពក្នុងគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីជាគុណប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។ ដើម្បីឲ្យការអភិវឌ្ឍប្រព្រឹត្តទៅដោយចីរភាព ការមានផែនការច្បាស់លាស់ យុទ្ធសាស្ត្រដ៏ត្រឹមត្រូវ គឺជារឿងត្រូវគិតគូរដោយប្រុងប្រយ័ត្ន។

ដើម្បីរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យនេះ ក្រុមការងារសហគមន៍ត្រូវបានបង្កើតឡើងជាពិសេស ក្នុងគោលដៅចុះផ្សព្វផ្សាយជូនប្រជាពលរដ្ឋ និងមហាជនទូទៅឲ្យបានយល់ច្បាស់ពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរអប្សរាក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ ក៏ដូចជាទទួលយកនូវសំណូមពរ ស្វែងរកនូវដំណោះស្រាយ និងការឧបត្ថម្ភគាំទ្រនានា សំដៅធ្វើឲ្យជីវភាពប្រជាពលរដ្ឋក្នុងតំបន់ការពារបេតិកភណ្ឌប្រសើរឡើង។ ដើម្បីធ្វើឲ្យការងារនេះកាន់តែមានប្រសិទ្ធភាព ការបង្កើតកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយអាជ្ញាធរដែនដី និងមូលដ្ឋាន គឺជាការងារអាទិភាពមួយទៀតរបស់អាជ្ញាធរអប្សរា។ក្នុងន័យនេះអាជ្ញាធរអប្សរាសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអាជ្ញាធរដែនដី និងមូលដ្ឋាន ជាពិសេសអភិបាលស្រុក-ក្រុង មេឃុំ ចៅសង្កាត់ និងមេភូមិ ក្នុងភូមិទាំង១១២ភូមិ ២១ឃុំ-សង្កាត់ នៃក្រុង-ស្រុកទាំង៥ ដែលក្រុមការងារសហគមន៍បាន និងកំពុងបំពេញសកម្មភាព ចំពោះការផ្តល់កិច្ចសហការល្អប្រសើរនាពេលកន្លងមក ហើយដែលបានរួមចំណែកយ៉ាងសំខាន់ ធ្វើឲ្យការងារទទួលបានជោគជ័យ និងដំណើរការរលូនទៅមុខ។ អាជ្ញាធរអប្សរា ក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការសហការ និងការយោគយល់របស់បងប្អូនប្រជាពលរដ្ឋ ក្នុងតំបន់បេតិកភណ្ឌ ដែលបានចូលរួមចំណែកក្នុងកិច្ចអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ដោយឡែកអាជ្ញាធរអប្សរានឹងបន្តបេសកកម្មតួនាទីនិងភារកិច្ចរបស់ខ្លួនក្នុងការងារអភិរក្ស និងអភិវឌ្ឍន៍ ដោយក្នុងនោះធ្វើយ៉ាងណាឲ្យប្រជាពរលដ្ឋក្នុងឧទ្យានអង្គរទទួលបានផ្លែផ្កាពិតប្រាកដចេញមកពីកិច្ចអភិវឌ្ឍ បន្តទប់ស្កាត់ជនចំណូលថ្មី ក្នុងគោលដៅដើម្បីកាត់បន្ថយការប្រើប្រាស់ដីថ្មីក្នុងឧទ្យានអង្គរ ដែលអាចជាមូលហេតុមួយធ្វើឲ្យប៉ះពាល់ដល់គុណតម្លៃអង្គរ។ អាជ្ញាធរអប្សរានឹងនៅតែបន្តយុទ្ធសាស្ត្រការងារ ក្នុងការងារគាំទ្រ និងឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលបានរស់នៅដ៏យូរលង់ ក្នុងឧទ្យានអង្គរ ស្របតាមសេចក្តីសម្រេចលេខ៧០របស់រាជរដ្ឋាភិបាល ដែលអនុញ្ញាតឱ្យបងប្អូនប្រជាពលរដ្ឋដែលមានលក្ខណៈវិនិច្ឆ័យដូចខាងលើបន្តរស់នៅភូមិដ្ឋាន បន្តជួសជុលផ្ទះចាស់ទ្រុឌទ្រោម ឬសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់ ក្រោមលក្ខខណ្ឌសុំការអនុញ្ញាតច្បាប់ពីអាជ្ញាធរអប្សរា ព្រមទាំងមានសិទ្ធិដទៃផ្សេងៗទៀត ស្របតាមបទបញ្ញត្តិជាធរមាន។

ក្នុងន័យនេះផងដែរ អាជ្ញាធរអប្សរា សូមអំពាវនាវដល់អាជ្ញាធរដែនដី/មូលដ្ឋាន និងប្រជាពលរដ្ឋរស់នៅក្នុងតំបន់បេតិកភណ្ឌគ្រប់គ្រងដោយអាជ្ញាធរអប្សរាបន្តកិច្ចសហការល្អប្រសើរនេះ ដើម្បីឱ្យស្របទៅនឹងការលើកឡើងថា "សហគមន៍ដើម្បីអង្គរ និងអង្គរដើម្បីសហគមន៍" ។

ព្រៃឈើជា កេរមរតកធម្មជាតិ និងវប្បធម៌ ដែលត្រូវការពារ ដើម្បីឱ្យរមណីយដ្ឋានអង្គរទាំងមូលប្រកបដោយទេសភាពស្រស់បំព្រង។ យើងខ្ញុំសូមអំពាវនាវដល់បងប្អូនក្នុងការចូលរួមការពារនិងដាំឡើងវិញ ដើម្បីជាផលប្រយោជន៍ចំពោះជីវៈចម្រុះ បរិស្ថាន និងភាពអស្ចារ្យនៃអាយុកាលប្រាសាទ។ អាជ្ញាធរអប្សរា មានការដ្ឋានបណ្តុះកូនឈើសម្រាប់បងប្អូនក្នុងការចូលរួមការពារបំណងដាំ ជាលក្ខណៈទ្រង់ទ្រាយតូច និងទ្រង់ទ្រាយធំ ដូចជានៅតាមសាលារៀន ទីប្រជុំជនភូមិ ទួលបុរាណ ទីសាធារណៈក៏ដូចជាដីភូមិរបស់បងប្អូនជាដើម។ ការស្នើសុំកូនឈើ ត្រូវផ្តល់ជូនដោយឥតគិតថ្លៃ។ ការងារអភិរក្សសត្វ និងរុក្ខជាតិតំបន់សៀមរាប-អង្គរ សូមឲ្យបងប្អូនចូលរួមទាំងអស់គ្នាជាមួយយើងខ្ញុំ។



លោក និន ចាន់សាមឿន
ប្រធាននាយកដ្ឋាន ទេសភាពវប្បធម៌
ព្រៃឈើ និងបរិស្ថាន



ឯកឧត្តម ហង់ ពៅ
អគ្គនាយករងអាជ្ញាធរអប្សរា
ទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក

ដើម្បីជួយសហគមន៍ក្នុងការអភិវឌ្ឍក្នុងតំបន់អង្គរ ការកែលម្អ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវ និង ប្រព័ន្ធធារាសាស្ត្របុរាណមាន ប្រឡាយ ស្ពាន ទំនប់ ទ្វារទឹក មិនត្រឹមតែអាចជួយដល់ការងារអភិរក្សប្រាង្គប្រាសាទប៉ុណ្ណោះទេ ថែមទាំងជួយការពារទឹកជំនន់មិនអោយជនលិចក្រុងសៀមរាបជាពិសេសយើងបានទាញយកប្រយោជន៍បម្រើដល់វិស័យកសិកម្មរបស់បងប្អូនក្នុងតំបន់អង្គរជាទិសដៅរបស់អាជ្ញាធរអប្សរា រីឯផលប្រយោជន៍នៃ ផ្លូវ ស្ពាន មិនត្រឹមតែអាចអនុញ្ញាតក្នុងការដឹកជញ្ជូនកសិផល និង ទំនាក់ទំនងរវាងបងប្អូនក្នុងរមណីយដ្ឋានអង្គរនោះទេ ស្ពាន ថ្នល់ ទាំងនេះបានបម្រើដល់ប្រជាជននៅក្បែរតំបន់រមណីយដ្ឋានអង្គរផងដែរ។

ជាការពិតណាស់ តំបន់អង្គរមានទំហំធំធេង ដែលត្រូវការពេលវេលា និងថវិកាដ៏ច្រើនក្នុងការស្តារនិងស្តាបនាឲ្យបានល្អប្រសើរឡើងវិញ។ សូមប្រជាពលរដ្ឋមេត្តាយោគយល់ចំពោះការងារអាជ្ញាធរអប្សរា ដោយសម្របសម្រួលរាល់ផលប៉ះពាល់នានា ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍ទាំងអស់គ្នា ដើម្បីប្រយោជន៍រួមរបស់ប្រទេសជាតិ ។ អាជ្ញាធរអប្សរាសូមអរគុណដល់ការសហការរបស់បងប្អូន។

យុវជនគឺជាចលករយ៉ាងសំខាន់ក្នុងកិច្ចការអភិវឌ្ឍន៍ប្រទេសជាតិ និងជាកម្លាំងស្នូលនៃការបន្តវេនសម្រាប់ដឹកនាំប្រទេសជាតិប្រកបដោយថាមពល និងប្រសិទ្ធភាព។ ការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គមលើគ្រប់វិស័យពិតជាមានសារៈសំខាន់ និងមិនអាចខ្វះបាន។ ក្នុងនោះការចូលរួមរបស់យុវជនលើកិច្ចការអភិរក្ស និងអភិវឌ្ឍន៍បេតិកភណ្ឌវប្បធម៌ក៏ជាផ្នែកមួយដែលត្រូវការជាចាំបាច់នៃការចូលរួមយ៉ាងសកម្មពីយុវជន។



ឯកឧត្តម សុខ សង្វា
អគ្គនាយករងអាជ្ញាធរអប្សរា
ទទួលបន្ទុកនាយកដ្ឋាន
អភិវឌ្ឍន៍ទេសចរណ៍អង្គរ
និងជាប្រធានក្រុមការងារ
អនុវត្តផែនការគ្រប់គ្រងទេសចរណ៍
(TMP)

វិស័យអប់រំគឺជាផ្នែកមួយយ៉ាងសំខាន់ចម្បងបង្អស់ដែលជាថ្នាលបណ្តុះបណ្តាលឲ្យយុវជនទទួលបាននូវចំណេះដឹង ការកសាងសមត្ថភាព ដើម្បីឆ្ពោះទៅកាន់គោលដៅនៃការសម្រេចបំណងរៀងៗខ្លួន។ អ្វីៗទាំងអស់គឺមិនអាចរំលងលើវិស័យអប់រំបានឡើយ។

អាជ្ញាធរអប្សរាជឿជាក់ថា នៅពេលដែលយុវជនបានយល់ដឹងនិងស្គាល់កាន់តែច្បាស់អំពីគុណតម្លៃបេតិកភណ្ឌវប្បធម៌ ពួកគាត់នឹងកាន់តែលើកតម្លៃហើយដើរតួជាអ្នកការពារ និងផ្សព្វផ្សាយកាន់តែទូលំទូលាយទៅកាន់អ្នកនៅជុំវិញខ្លួននិងជាសកល។

តាមរយៈក្រុមការងាររបស់យើងខ្ញុំ មានគោលដៅចម្បងបំផុតគឺការជួបផ្ទាល់ជាមួយ សិស្សនិស្សិត តាមបណ្តាលអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់ក្នុងតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រ-អង្គរ និងតាមសាកលវិទ្យាល័យនានាក្នុងខេត្តសៀមរាប ដើម្បីផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីសមិទ្ធផលទាំងឡាយនិងកិច្ចការងារយ៉ាងសំខាន់របស់អាជ្ញាធរអប្សរាក្នុងកិច្ចការ អភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរប្រកបដោយចីរភាព។



លោក ជ្រុន សុផល
ឧបការី និងជាប្រធានលេខាធិការដ្ឋាន
សហគមន៍អាជ្ញាធរអប្សរា
របស់អាជ្ញាធរជាតិអប្សរា

ក្រុមការងារសហគមន៍ បានចុះទៅជួយដោះទុក្ខកង្វល់របស់ប្រជាពលរដ្ឋជាប្រចាំដល់ទីកន្លែងតែម្តង គឺដោះស្រាយបញ្ហានានាដូចជា ការសុំសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់ ការជួសជុល និងសំណង់នានាជូនពួកគាត់។ ទន្ទឹមនឹងនោះ ក្រុមការងារនេះ បានចុះសួរសុខទុក្ខ ពន្យល់ណែនាំដាស់តឿនពីអនាម័យក្នុងភូមិ ថែមទាំងនាំយកកញ្ចប់ទ្រទ្រង់សុខភាពម្តាយ និងទារកជូនដល់បងប្អូនស្ត្រីដែលទើបតែសម្រាលកូនក្នុងតំបន់រមណីយដ្ឋានអង្គរ ជាប្រចាំផងដែរ។

ដើម្បីជំរុញការអភិវឌ្ឍ ក្រុមការងារសហគមន៍យើងបាននាំយកសំណើររបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងសមិទ្ធផលសាធារណៈ មករាយការណ៍ជូនឯកឧត្តមអគ្គនាយកចាត់ចែងក្រុមអ្នកជំនាញទៅសិក្សា, សំណើខ្លះ បងប្អូនបានប្រើប្រាស់ថវិកាភូមិឃុំ សំណើខ្លះទៀត អាជ្ញាធរអប្សរាធ្វើជូនទាំងស្រុង សមិទ្ធផលជាច្រើនសុទ្ធតែជាញើសឈាមដែល ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរចាប់ដៃកសាងរួមគ្នាជាមួយអាជ្ញាធរអប្សរា វាបានបង្ហាញឲ្យឃើញកាន់តែច្បាស់ពីភាតរភាពវាងអាជ្ញាធរអប្សរា ជាមួយបងប្អូនក្នុងសហគមន៍នៃរមណីយដ្ឋានអង្គរ ។



ឯកឧត្តម មុី ម៉ារ៉ាឌី
ទីប្រឹក្សាអាជ្ញាធរអប្សរា
ប្រធានគម្រោងអភិវឌ្ឍន៍
ភូមិធម្មជាតិរុនតាឯក

សំណួរថា «តើអាជ្ញាធរអប្សរាគិតគូរយ៉ាងណាចំពោះកំណើនប្រជាជន និងតម្រូវការបំបែកខ្នងផ្ទះរបស់កូនចៅអ្នកដែលរស់នៅតំបន់ការពារទីមួយនិងទីពីរក្នុងរមណីយដ្ឋានអង្គរ ? »។

អាជ្ញាធរអាប្សរា បានគិតគូររួចជាស្រេច ហើយបានបង្កើតភូមិអភិវឌ្ឍន៍ថ្មីមួយ ដែលមានឈ្មោះថា «ភូមិធម្មជាតិរុនតាឯក» ព្រមទាំងការផ្តល់សម្ភារៈសំណង់ ដីឡូដ៍សង់ផ្ទះ និងចំការជូនចំនួន១ហិកតា។ នៅទីនោះមាន ផ្លូវ ប្រឡាយ សាលារៀន ទីសក្ការៈសាសនា ទីផ្សារការងារ និងទេសចរណ៍។ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងគ្រួសារ អាជ្ញាធរអប្សរាផ្តល់ការងារនៅនឹងកន្លែងជាការងារដែលមានស្រាប់នៅក្នុងភូមិ ថែមទាំងមានកម្មវិធីបណ្តុះបណ្តាល សិប្បកម្ម និង កសិកម្មជូនដល់បងប្អូនដែលត្រូវការជំនាញបន្ថែម។ ភាពស្និទ្ធស្នាលស្រឡាញ់រាប់អានគឺពិតជាមានរវាងថ្នាក់ដឹកនាំបុគ្គលិក របស់អាជ្ញាធរអប្សរា ជាមួយបងប្អូនដែលមកតាំងទីរស់នៅនេះយើងអាចនិយាយបានថា យើងជា មហាគ្រួសារនៅភូមិធម្មជាតិរុនតាឯក។



ឯកឧត្តម ខូយ គឹមទូ
ទីប្រឹក្សាអាជ្ញាធរអប្សរា
ប្រធានដោះស្រាយគោលនយោបាយដីធ្លី

អាជ្ញាធរអប្សរាឈរលើគោលការណ៍ ដោះស្រាយគោលនយោបាយដីធ្លី ជូនប្រជាពលរដ្ឋចំពោះផលប៉ះពាល់ទៅលើបងប្អូនប្រជាពលរដ្ឋ ដែលកើតចេញពីគម្រោងអភិរក្ស និងអភិវឌ្ឍន៍តំបន់បុរាណវត្ថុវិទ្យា។ កន្លងមក យើងបានដោះស្រាយ ប្រាក់គោលនយោបាយ ដីបុរីវប្បធម៌ និងទេសចរណ៍ លើសពីនេះទៅទៀត អាជ្ញាធរអប្សរាបានដោះស្រាយគោលនយោបាយ ដើម្បីរៀបចំភូមិធម្មជាតិរុនតាឯក ដោះស្រាយផលបះពាល់ក្នុងការងារ ស្តារប្រព័ន្ធធារាសាស្ត្របុរាណដែលប៉ះទៅលើស្រែចម្ការ និងភូមិដ្ឋានរបស់បងប្អូនប្រជាពលរដ្ឋ សូមបងប្អូនទទួលស្គាល់ថាការរក្សាឲ្យមាននូវតម្លៃ និងសណ្តាប់ធ្នាប់ក្នុងរមណីយដ្ឋានអង្គរដែលជាកិត្តិយសរបស់ជាតិខ្មែរ។

ដើម្បីឲ្យការងារអភិរក្ស និងអភិឌ្ឍន៍តំបន់សៀមរាប-អង្គរ ប្រកបដោយចីរភាព យើងទាំងអស់គ្នាចំបាច់ត្រូវឈរលើគោលជំហរយកប្រយោជន៍រួមជាធំ ហើយដដែកគ្នាក្នុងនាមជាបងប្អូន។



ឯកឧត្តម សុខ លក្ខិណា
ទីប្រឹក្សាអាជ្ញាធរអប្សរា
ប្រធាន និងជាអ្នកតំណាងគ្រប់គ្រងបរិស្ថាន
អង្គរ

ឈរលើមូលដ្ឋានអភិវឌ្ឍន៍ស៊ីសង្វាក់រវាង "ធម្មជាតិ ប្រាសាទ និងអ្នកស្រុក" អាជ្ញាធរអប្សរាមានគោលនយោបាយក្នុងការលើកស្ទួយបរិស្ថានក្នុងតំបន់អង្គរ ដោយជំរុញបង្ការផលប៉ះពាល់បរិស្ថាន ឲ្យស្របទៅតាមកំណើនភ្ញៀវទេសចរ ។ ដើម្បីរៀបចំបរិស្ថានក្នុងតំបន់អង្គរយើងបានបង្កើតប្រព័ន្ធគ្រប់គ្រងសំរាម ដោយសម្អាត ជាប្រចាំនូវទីលានជុំវិញប្រាសាទ បារាយណ៍ត្រពាំង និងព្រៃឈើ ដែលធ្វើឲ្យបរិយាកាសនិងសោភណភាពតំបន់អង្គរមានភាពកាន់តែប្រសើរឡើង។ ការអប់រំផ្សព្វផ្សាយអំពីបរិស្ថានជូនដល់ប្រជាជនដែលរស់នៅនិងប្រកបរបររកស៊ីក្នុងតំបន់រមណីយដ្ឋានអង្គរគឺពិតជាការចាំបាច់ដើម្បីជំរុញការចូលរួមសហការ គោរពច្បាប់បញ្ញត្តិ។ ធ្វើការកែលម្អជាប្រចាំ រាល់ទង្វើទាំងឡាយណាដែលអាចនាំឲ្យមានផលប៉ះពាល់មកលើបរិស្ថានអង្គរ។

គ្រប់នាយកដ្ឋានរបស់អាជ្ញាធរជាតិអប្សរា បានប្រើប្រាស់នូវគោលនយោបាយបរិស្ថានក្នុងការបំពេញការងារលើកតម្លៃអ្នកស្រុកអង្គរ ដែលជាកម្លាំងចលករក្នុងការថែរក្សាឲ្យមានភាពប្រសើរឡើងជានិរន្តរ៍ នៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ។

# សម្លេងសហគមន៍
# នៃរមណីយដ្ឋានអង្គរ



លោក ហួត ហាយ ប្រធានសមាគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ខាងលិច ក្នុងពេលដែលលោកកំពុងដឹកនាំប្រជាពលរដ្ឋសម្អាតប្រឡាយ

សមាគមន៍យើងមានប្រជាពលរដ្ឋ៩ឃុំសង្កាត់ និងមានផ្ទៃដីធ្វើស្រែប្រាំងចំនួនបួនពាន់ហិកតា ចាប់តាំងពីអាជ្ញាធរជាតិអប្សរាបានទទួលការគ្រប់គ្រង ប្រព័ន្ធទឹកនៅបារាយណ៍ខាងលិចមក កសិករយើងមានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់បង្កបង្កើនផល មិនមានការបារម្ភណ៍ពីកង្វះខាតទឹកនោះទេ ហើយការសម្អាតប្រឡាយនៅពេលនេះគឺជួយសម្រួលទឹកឲ្យបានហូរលឿន។



ជំទប់ទី១នៃឃុំខ្នាត ស្រុកពួក លោក មឿន ឈឿត ស្រែប្រាំងនៅក្នុងឃុំរបស់យើងមាន៣៨០ហិកតា យើងទាំងអស់គ្នារីករាយជាខ្លាំង ដែលអាជ្ញាធរអប្សរាបានជួយស្តារនិងកាយប្រឡាយចាស់ៗមួយចំនួនក្នុងឃុំរបស់យើងខ្ញុំ បានប្រើប្រាស់ឡើងវិញ។សព្វថ្ងៃរាល់សំណូមពររបស់ប្រជាពលរដ្ឋទាក់ទងនឹងទឹកធ្វើកសិកម្ម អាជ្ញាធរអប្សរាតែងជួយដោះស្រាយទាន់ពេលវេលាមិនដែលខកខានឡើយ។



លោកអ៊ំ ស្វាយ ហុង មេឃុំដូនកែវ ស្រុកពួក

ក្នុងឃុំដូនកែវមាន១៣ភូមិ ប្រជាជនក្នុងភូមិនេះប្រកបរបកសិកម្ម៩០%។ក្នុងលទ្ធផលដែលយើងធ្វើទំនប់នេះអាចស្រោចស្រង់បាន៨-៩ភូមិ។ ក្រោយពីឆ្នាំ១៩៧៩ ប្រជាពលរដ្ឋយើងបានធ្វើទំនប់នេះ តែឆ្នាំនេះដោយមានគុណដែលមានអាជ្ញាធរអប្សរារបស់យើង រាជរដ្ឋាភិបាលយើងបានចុះសិក្សា ត្រួតពិនិត្យ ដើម្បីធ្វើប្រព័ន្ធបញ្ចៀសទឹកពីក្រុងសៀមរាប ក្រុងអង្គរ និងដើម្បីឃុំដូនកែវ។



បងស្រី យី សាលីន និងគ្រួសារ ជាកសិករនៅភូមិ-ឃុំលាងដៃ ស្រុកអង្គរធំ ដែលតែងតែធ្វើដំណើរឆ្លងកាត់តាមផ្លូវនេះ អរគុណខ្លាំងណាស់ដែលអាជ្ញាធរអប្សរាបានស្ថាបនាផ្លូវនេះឡើង ឲ្យខ្ញុំនិងអ្នកស្រុកក្នុងឃុំលាងដៃបានធ្វើដំណើរស្រួល ចង់ទៅទិញម្ហូប ឬយកអីវ៉ាន់ទៅលក់ដូរនៅផ្សារក៏លឿន ទៅប្រាសាទក៏លឿនចង់ដើរក៏ស្រួលមិនដូចពីមុន ឱ្យតែខែភ្លៀងម្ដងៗគឺយ៉ាប់ចិត្តណាស់ ផ្លូវក្រឡិកក្រឡុក ដើរជាប់ជើង បើជិះម៉ូតូវិញ គឺជិះទៅមិនកើតទេ ទាល់តែទុកនៅជ្រុងម្ខាង ហើយដើរទៅបានរួច។ ខ្ញុំអរគុណមែនទែន! ហើយខ្ញុំសប្បាយចិត្តណាស់ដែលបានផ្លូវថ្មីនេះ។



លោក ហម ហន ក៏បានថ្លែងអំណរគុណចំពោះអាជ្ញាធរអប្សរា ដែលតែងតែយកចិត្តជួយលើកតម្កើងជីវ-ភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈ ការរៀបចំគម្រោង និង កសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលបម្រើដល់ការប្រើប្រាស់ប្រចាំថ្ងៃ។ ប្រជាពលរដ្ឋយើងត្រូវចេះស្រឡាញ់ និងរក្សាផ្លូវថ្នល់ឲ្យបានគង់វង្សយូរអង្វែង ព្រោះនេះជាផ្លូវរបស់យើងទាំងអស់គ្នា។



លោក ភាគ សាវឿន គឺជាប្រធានក្រុមនៃក្រុម

សន្សំប្រាក់ភូមិជ័យ ស្រុកពួក។ លោកបានបញ្ជាក់ក្នុងពិធីបិទបញ្ជីក្រុមប្រចាំឆមាសទី១ នាព្រឹកថ្ងៃទី២០ ខែកញ្ញាថា ក្រុមសន្សំប្រាក់របស់លោកបានបង្កើតឡើងរយៈពេលជិត ៧ឆ្នាំហើយ។ ក្រុមនេះបានរីកចម្រើនខ្លាំងតាំងពីមានសមាជិក៩រូបជាមួយនឹងទុន១លាន៦០ម៉ឺនរៀលក្នុងពេលបង្កើត។



លោកស្រី ឈ្មោះ លន់ សុខុន រស់នៅភូមិប្រឡាយ ឃុំខ្នាត ស្រុកពួក ខ្ញុំមានចិត្តសប្បាយរីករាយណាស់ដែលបានអាផ្វាធរអេប្សរាចុះជួយដល់ប្រជាពលរដ្ឋ យើងខ្ញុំសំ-ណូមពរឱ្យអាផ្វាធរអេប្សរា មានកម្មវិធីនេះ(សម្ភារៈទ្រទ្រង់សុខភាពម្ដាយ និងទារក)រហូតតទៅដើម្បីជួយដល់គ្រួសារស្រ្តីកូនខ្ចីដែលមានជីវភាពលំបាក។



លោក ទូច ឈន់ មេឃុំប្រដាក ស្រុកបន្ទាយស្រី

អាផ្វាធរអេប្សរាបានជួយច្រើនណាស់ ឱ្យតែយើងទៅសុំគឺបានហើយ គេជួយដូចជា ធ្វើទ្វារទឹក ស្ពានប្រឡាយបញ្ជូលទឹកដាក់ស្រែឱ្យយើង។

ហើយមួយទៀតការសុំសង់ផ្ទះឱ្យតែយើងនៅយូរហើយ យើងសុំបាន ណាស់តែយើងធ្វើវាមិនត្រូវតាមបែបបទគេ។ បើនិយាយពីជីវភាពវិញ អាផ្វាធរអេប្សរាក៏មានរៀបចំឱ្យមានសហគមន៍នេះ សហគមន៍នោះអ៊ីចឹងទៅគឺគេជួយឲ្យមានការងារធ្វើក្បែរៗហ្នឹង ។ ប្រជាពលរដ្ឋដែលគេចូលរួមធ្វើ ជាមួយអាផ្វាធរអេប្សរាក៏គេចេះតែធូរធារទៅៗ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ១៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសហគមន៍ចំណុះឱ្យអគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១ន.ស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ«អប្សរា»
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ«អប្សរា»ឱ្យស្របជាមួយបទបញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលមាត្រា៤និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ«អប្សរា»
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០១០៧/០១៥ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលមាត្រា២ ជំពូក១នៃព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ«អប្សរា»
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកែរ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៥/៣២៣ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរ«អប្សរា»
- បានឃើញអនុក្រឹត្យលេខ១២ អនក្រចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទបេងមាលា
- បានឃើញអនុក្រឹត្យលេខ៥០អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញសេចក្តីសម្រេចលេខ៧០សសរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅក្នុងតំបន់១ និងតំបន់២ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមការចាំបាច់របស់អាជ្ញាធរជាតិអប្សរា

## សម្រេច

**ប្រការ១**: បង្កើតក្រុមការងារសហគមន៍ចំនួន៧ក្រុម ស្ថិតនៅក្រោមការសម្របសម្រួល និងដឹកនាំផ្ទាល់ពីអគ្គនាយកអាជ្ញាធរជាតិអប្សរា។

**ប្រការ២**: ក្រុមការងារសហគមន៍ខាងលើ មានសមាសភាពដូចខាងក្រោម៖

**ក-ក្រុមទី១** ( ស្រុកប្រាសាទបាគង)

| | | |
|---|---|---|
| ១- ឯកឧត្តម | **សុខ លក្ខិណា** | ប្រធាន |
| ២- លោក | **ទ៉ាន់ ដានី** | អនុប្រធាន |
| ៣- លោកស្រី | **ម៉ៅ ល្អ** | អនុប្រធាន |
| ៤- លោក | **ចាន់ វឌ្ឍនា** | អនុប្រធាន |
| ៥- លោក | **ភ័ន ផល្លា** | អនុប្រធាន |
| ៦- លោក | **ឈីវ ណាំ** | សមាជិក |
| ៧- លោក | **ជូ វ៉ាឌីណា** | សមាជិក |
| ៨- លោក | **រស់ រដ្ឋធានី** | សមាជិក |
| ៩- លោក | **ស៊ឹម ថន** | សមាជិក |
| ១០- លោក | **តាន់ សុផល** | សមាជិក |
| ១១- លោក | **ម៉ុក គន្ធី** | សមាជិក |
| ១២- លោក | **រស់ វិសុទ្ធ** | សមាជិក |
| ១៣- លោក | **ចាន់ ពន្លឺ** | សមាជិកអចិន្ត្រៃយ៍ |
| ១៤- លោក | **ទស្ស សុមនាថ** | សមាជិក |
| ១៥- លោក | **ស្រេង ម៉េងឃាង** | សមាជិក |
| ១៦- លោក | **ផង បញ្ញា** | សមាជិក |
| ១៧- លោក | **ម៉ៅ រតនា** | សមាជិក |
| ១៨- លោក | **ស៊ុន ចាន់ធូ** | សមាជិក |
| ១៩- លោក | **ទូច តេត្រា** | សមាជិក |
| ២០- លោក | **លាន សុវ៉ាឡុង** | សមាជិក |

**ខ-ក្រុមទី២** ( ស្រុកអង្គរជ័)

១- ឯកឧត្តម **ហង់ ពៅ** ប្រធាន

២- ឯកឧត្តម **ឃួន ឃុននាយ** អនុប្រធាន

៣- ឯកឧត្តម **សឹង គង់** អនុប្រធាន

៤- ឯកឧត្តម **ត័ន ប៊ុនស៊ុយ** អនុប្រធាន

៥- លោក **លី វណ្ណា** អនុប្រធាន

៦- លោក **ព្រហ្ម សំអ៊ាន** សមាជិក

៧- លោក **តឿន សុឃីម** សមាជិក

៨- លោក **ទេព គូនី** សមាជិក

៩- លោក **សេង សុធារ៉ា** សមាជិក

១០- លោក **ម៉េង វណ្ណី** សមាជិក

១១- លោក **វ៉ា សុភ័ក្រ្ត** សមាជិកអចិន្ត្រៃយ៍

១២- លោក **ម៉ៅ សុខនី** សមាជិក

១៣- លោក **គីង ដារា** សមាជិក

១៤- លោក **ស្រ៊ុន តិច** សមាជិក

១៥- លោក **ប៊ី សុភាព** សមាជិក

១៦- លោក **បេង ប៊ីន** សមាជិក

១៧- លោក **ញ៉ែម រស្មី** សមាជិក

១៨- លោក **ប៉ាត់ ឌីណា** សមាជិក

១៩- លោក **សឿង វឌ្ឍនា** សមាជិក

**គ-ក្រុមទី៣** ( ស្រុកពួក)

១- ឯកឧត្តម **ឈរ ថាណាត** ប្រធាន

២- លោក **និន ចាន់សាម៉ៀន** អនុប្រធាន

៣- លោក **ព្រំ ករុណា** អនុប្រធាន

៤- លោក **ឃិន សុវ៉ាត** សមាជិក

៥- លោក **ស្វាយ ពិសិដ្ឋ** សមាជិក

៦- លោក **នៅ សម្រេច** សមាជិក

៧- លោក **ចេវ ផល** សមាជិក

៨- លោក **មាស ប៊ុនឡាប** សមាជិក

៩- លោកស្រី **ប៊ុន សុជាតា** សមាជិក

១០- លោក **អឿន សំអុន** សមាជិកអចិន្ត្រៃយ៍

១១- លោក **ឈួន សាម៉ីឌី** សមាជិក

១២- លោក **សុខ សារ៉ាន់ឌី** សមាជិក

១៣- លោក **កើត វិទ្យា** សមាជិក

១៤- លោក **អន សុភាព** សមាជិក

១៥- លោក **លី ពុទ្ធា** សមាជិក

១៦- លោក **ឡៃ ប៉ូទី** សមាជិក

១៧- លោក **ទូច រាសី** សមាជិក

**ឃ-ក្រុមទី៤** ( ក្រុងសៀមរាប)

| | | |
|---|---|---|
| ១- ឯកឧត្តម | **ខួយ គឹមទួ** | ប្រធាន |
| ២- លោកជំទាវ | **ចៅ ស៊ិន ភិរិយា** | អនុប្រធាន |
| ៣- ឯកឧត្តម | **អ៊ុក សូមេត្ត** | អនុប្រធាន |
| ៤- ឯកឧត្តម | **តាន់ សំប៊ុន** | អនុប្រធាន |
| ៥- លោក | **លឹម អូភ** | អនុប្រធាន |
| ៦- លោក | **អ៊ុំម សុខរិទ្ធី** | សមាជិក |
| ៧- លោក | **គ្រឹម វីរៈ** | សមាជិក |
| ៨- លោក | **ទិន ទីណា** | សមាជិក |
| ៩- លោក | **លឹម ស្រ៊ុ** | សមាជិក |
| ១០- លោក | **ឆុខ វីរ៉ា** | សមាជិក |
| ១១- លោក | **ទិត្យ សុផា** | សមាជិក |
| ១២- លោក | **ដែខ សម្បត្តិ** | សមាជិក |
| ១៣- លោក | **សូរ សារ៉ម** | សមាជិក |
| ១៤- លោក | **យឹម សាន់ខេ** | សមាជិកអចិន្ត្រៃយ៍ |
| ១៥- លោក | **ទីម ម៉េខលីម** | សមាជិក |
| ១៦- លោក | **សឿន ម៉ៅ** | សមាជិក |
| ១៧- លោក | **យឹម រ៉ាឌី** | សមាជិក |
| ១៨- លោក | **សូម៉ា សូភា** | សមាជិក |
| ១៩- លោក | **ថាន់ តារាសាស្ត្រ** | សមាជិក |
| ២០- លោក | **សាម៉ុន សុធារ៉ា** | សមាជិក |
| ២១- លោក | **មាន់ ផានិត** | សមាជិក |
| ២២- លោក | **សូ សារិន** | សមាជិក |
| ២៣- លោក | **ជិន សុខម៉េខ** | សមាជិក |
| ២៤- លោក | **យាម មុន្នី** | សមាជិក |

**ខ-ក្រុមទី៥** ( ស្រុកបន្ទាយស្រី)

| | | |
|---|---|---|
| ១- ឯកឧត្តម | **ម៉ុ ម៉ារ៉ាឌី** | ប្រធាន |
| ២- លោក | **ជ្រុន សុផល** | អនុប្រធាន |
| ៣- លោក | **ម៉ែត សុទ្ធី** | អនុប្រធាន |
| ៤- លោក | **ហ៊ូ ស៊ាប** | អនុប្រធាន |
| ៥- លោក | **នខ សុវណ្ណារិទ្ធ** | សមាជិកអចិន្ត្រៃយ៍ |
| ៦- លោក | **អ៊ុំ សុផា** | សមាជិក |
| ៧- លោក | **លី សុណារ៉េត** | សមាជិក |
| ៨- លោក | **ជា មិនា** | សមាជិក |
| ៩- លោក | **ស្ងួន បូរ៉េត** | សមាជិក |
| ១០- លោក | **តូច សុភៈ** | សមាជិក |
| ១១- លោក | **សេន សែត** | សមាជិក |

១២- លោក **ហ៊ីម សីហា** សមាជិក
១៣- លោក **ហ៊ិន ឡាមុនី** សមាជិក
១៤- លោក **សយ សុតារិទ្ធ** សមាជិក

**ច-ក្រុមទី៦** (តំបន់ពាក់ព័ន្ធ ក្រៅឧទ្យានអង្គរ)

១- លោក **ឈាន រដ្ឋា** ប្រធាន
២- លោក **រ៉ា ដារិទ្ធ** អនុប្រធាន
៣- លោក **សំ សារ៉េត** សមាជិកអចិន្ត្រៃយ៍
៤- លោក **អ៊ិន សុវណ្ណា** សមាជិក
៥- លោក **សន សិត្ថា** សមាជិក
៦- លោក **ឮ ចាន់ណារ៉ា** សមាជិក
៧-លោកស្រី **ម៉ៅ សុម៉ាតិវឌ្ឍន៍** សមាជិក
៨- លោក **ម៉ុន ចំរើន** សមាជិក
៩- លោក **រ៉េន ម៉ុនថន** សមាជិក
១០- លោក **ពុំ វិចិត្រ** សមាជិក
១១- លោក **គាត ម៉េងគាង** សមាជិក

**ឆ-ក្រុមទី៧** ( អនុវិទ្យាល័យ វិទ្យាល័យ សាកលវិទ្យាល័យ )

១- ឯកឧត្តម **រស់ មូរ៉ាត** ប្រធានកិត្តិយស
២- ឯកឧត្តម **សុខ សទ្វារ** ប្រធាន
៣- លោក **ហុក ម៉េងសែ** អនុប្រធាន
៤- លោក **ហេង គីមលេង** អនុប្រធាន
៥- លោក **ឡុង កុសល** អនុប្រធាន
៦- លោក **ច័ន្ទ សុធា** សមាជិកអចិន្ត្រៃយ៍
៧- លោកស្រី **អ៊ុំ ម៉ារ៉ាឌី** សមាជិក
៨- លោកស្រី **ម៉ម វណ្ណារតន៍** សមាជិក
៩- កញ្ញា **សោម គន្ធា** សមាជិក
១០- លោក **អាង ភក្តី** សមាជិក
១១- កញ្ញា **ឯម ស្រីពៅ** សមាជិក
១២- លោក **ខៀវ ច័ន្ទ** សមាជិក
១៣-លោក **ម៉ុត លីណា** សមាជិក
១៤- លោក **ទេស សុធីរ** សមាជិក
១៥- លោក **ស៊ិន ពិសី** សមាជិក
១៦- លោក **ហាក់ រិទ្ធី** សមាជិក
១៧- លោក **សេង ចន្ថា** សមាជិក

**ប្រការ៣**: ក្រុមការងារសហគមន៍ទាំង៧ខាងលើ មានភារកិច្ចដូចខាងក្រោម៖

– សហការជាមួយនាយកដ្ឋានផ្សព្វផ្សាយ ដើម្បីចុះផ្សព្វផ្សាយ និងផ្តល់ព័ត៌មានជូនប្រជាជនតាមសហគមន៍ និងប្រជាជនរស់នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងតំបន់ពាក់ព័ន្ធ

- ចុះផ្សព្វផ្សាយឱ្យប្រជាជនបានយល់ដឹងអំពីតួនាទីរបស់អាជ្ញាធរជាតិអប្សរា សមិទ្ធផលការងារថ្មីៗដែលសម្រេចបាន ព្រមទាំងអំពីផលប្រយោជន៍នៃកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ដែលកំពុងអនុវត្តដោយអាជ្ញាធរជាតិអប្សរា
- ចុះផ្សព្វផ្សាយនិងជូនព័ត៌មានដល់ប្រជាជនតាមសហគមន៍ និងប្រជាជនរស់នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងតំបន់ពាក់ព័ន្ធឱ្យយល់ដឹងច្បាស់អំពីតម្លៃនៃការអភិរក្ស និងអភិវឌ្ឍន៍សម្បត្តិបេតិកភណ្ឌ និងវប្បធម៌
- ចុះផ្សព្វផ្សាយអប់រំជូនសិស្សនិស្សិតតាមបណ្តាអនុវិទ្យាល័យ វិទ្យាល័យក្នុងតំបន់រមណីយដ្ឋានអង្គរ និងសាកលវិទ្យាល័យនានាក្នុងខេត្តសៀមរាប
- ស្ទាបស្ទង់ និងបូកសរុបការវាយតម្លៃរបស់ប្រជាជនចំពោះការងាររបស់អាជ្ញាធរជាតិអប្សរា
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនអគ្គនាយក និងជូនប្រធានអាជ្ញាធរជាតិអប្សរា
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិអប្សរាប្រគល់ជូន ។

**ប្រការ៤:** ក្រុមការងារសហគមន៍ខាងលើ មានក្រុមលេខាធិការដ្ឋានជាសេនាធិការ ក្នុងការបូកសរុបការងារតាមដាន និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក | **ឡុង សុផល** | ប្រធាន |
| ២. លោក | **ឈឹម ស៊្រី** | អនុប្រធាន |
| ៣. លោក | **ឡឿន សំអុន** | អនុប្រធាន |
| ៤. លោក | **ចាន់ ពន្លឺ** | សមាជិក |
| ៥. លោក | **ចៅ សុភ័ក្ត្រ** | សមាជិក |
| ៦. លោក | **ឈឹម សារ៉េន** | សមាជិក |
| ៧. លោក | **ខង សុវណ្ណារិទ្ធ** | សមាជិក |

**ប្រការ៥:** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា ត្រូវជួយដោះស្រាយការិយាល័យ ថវិកា សម្ភារៈ និងបុគ្គលិកមួយចំនួនតាមការចាំបាច់ តាមការស្នើសុំរបស់ក្រុមការងារ ដើម្បីជួយឱ្យក្រុមការងារអាចសម្រេចបានលទ្ធផលល្អប្រសើរ ។

**ប្រការ៦:** សេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មការការងារសហគមន៍ និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧:** អគ្គលេខាធិការរាជរដ្ឋាភិបាល អគ្គនាយកអាជ្ញាធរជាតិអប្សរា ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រីនិងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- សាលាខេត្តសៀមរាប
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ


អាជ្ញាធរអប្សរា
ឆ្នាំ២០១៦